សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiuques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# កិច្ចសន្យាលក់ទិញអចលនវត្ថុ នៅបុរី វិមានស

ស្រាវជ្រាវចាប់ពីថ្ងៃ ទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ : លោក **សុត វាសនា**

កញ្ញា **ទូច ស្រីនិច**

សាស្ត្រាចារ្យណែនាំ

លោក **ឌិន វណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **សុត វាសនា** និង នាងខ្ញុំ **ទូច ស្រីនិច** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា ២០១៤-២០១៨ សូមសម្ដែងនូវកតញ្ញូតាធម៌ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

សូមលើកអញ្ជលីលំឱនកាយវាចាចិត្តគោរពដល់៖

- លោកឪពុក **នុត ស៊ីន**
- អ្នកម្ដាយ **ស៊ូ ស្រី**
- លោកឪពុក **ទូច សុខល័ក្ខ**
- អ្នកម្ដាយ **វណ្ណា សុធា**
- លោកតា **ហាក់ ទូច**
- លោកយាយ **ស្រូយ សៀកលីវ**

ដែលបានផ្ដល់កំណើត ផ្ដល់សេចក្ដីស្រឡាញ់ ផ្ដល់ដំបូន្មាន ផ្ដល់ការអប់រំ និងបានជួយឧបត្ថម្ភគាំទ្រផ្នែកថវិកា ការលើកទឹកចិត្ត និងជម្រុញស្មារតី ដើម្បីផ្ដល់មធ្យោបាយឲ្យយើងខ្ញុំបានក្រេបជញ្ជក់យកនូវចំណេះដឹង រហូតដល់ថ្នាក់បញ្ញាបត្រនេះ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយទេពកោសល្យដ៏ប៉ិនប្រសប់គ្មានគូរប្រៀបរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ទាំងលើសមរភូមិការទូត និងអន្តរជាតិ ទាំងលើសមរភូមិសេដ្ឋកិច្ច និងសង្គមកិច្ច ទាំងលើសមរភូមិការពារអធិបតេយ្យ និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដែលជាហេតុបានផ្ដល់នូវសន្តិភាព ជាឱកាសឲ្យយើងខ្ញុំបានសិក្សាក្រេបយកចំណេះវិជ្ជា ដើម្បីជាស្ពានឈានទៅអនាគត។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យយើងខ្ញុំ បានចូលសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និង បង្កលក្ខណៈងាយស្រួលដល់ការសិក្សា របស់យើងខ្ញុំ។

លោកសាស្ត្រាចារ្យ **ខិន ទណ្ណារ៉ា** ជាសាស្ត្រាចារ្យណែនាំ ដែលបានឆ្លៀតឱកាសដ៏មមាញឹកក្នុងការបង្ហាត់បង្ហាញផ្តល់ការណែនាំ ថែមទាំងផ្តល់នូវឯកសារមួយចំនួនដល់យើងខ្ញុំ ដើម្បីរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះឡើង។

សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យបុគ្គលិកសិក្សា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលបានបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមប្រសិទ្ធិពរជ័យសិរីបវរជូនដល់ លោកឪពុកអ្នកម្តាយ យាយតា ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរសព្រឹទ្ធបុរសរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ឲ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាអស់រយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្ររួចមក យើងខ្ញុំបានទទួលនូវចំណេះដឹងយ៉ាងច្រើនពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ ជាពិសេសគឺលោកសាស្ត្រាចារ្យណែនាំ។ នៅក្នុងអំឡុងពេលសិក្សាកន្លងមកនេះយើងខ្ញុំពិតជាមានការពេញចិត្ត និងមានការចាប់អារម្មណ៍ទៅលើគ្រប់មុខវិជ្ជាទាំងអស់ ប៉ុន្តែអ្វីដែលសំខាន់ដែលធ្វើឲ្យយើងខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងនោះគឺ ទៅលើវិស័យរដ្ឋប្បវេណី ដែលនាំឲ្យយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី "**កិច្ចសន្យាលក់ទិញអចលនវត្ថុនៅបុរីវិមាន ស**" ធ្វើជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវក្នុងសារណាបញ្ចប់ការសិក្សានេះ។

ដោយសារតែ នាពេលបច្ចុប្បន្នវិស័យអចលនវត្ថុនៅកម្ពុជា កំពុងតែមានសន្ទុះដែលជាហេតុធ្វើឲ្យ ប្រតិបត្តិការការលក់ទិញកើតមានឡើងគួរឲ្យកត់សម្គាល់។ ម្យ៉ាងដោយសារតែការលក់ទិញមានការរីកចម្រើន ដូចនេះត្រូវតែមាននូវយន្តការដើម្បីធ្វើការការពារចំពោះការលក់ទិញអចលនវត្ថុនេះប្រកបដោយលក្ខណៈត្រឹមត្រូវ។

កត្តាទាំងអស់ខាងលើនេះ បានជម្រុញឲ្យយើងខ្ញុំ ជ្រើសរើសយកប្រធានបទដូចបានបង្ហាញខាងលើ មកធ្វើជាកម្មវត្ថុនៃសារណាបញ្ចប់ការសិក្សានេះ។ នៅក្នុងការចងក្រងសារណានេះយើងខ្ញុំបានផ្អែកទៅលើអត្ថបទច្បាប់នានា ដែលទាក់ទងទៅនឹងកិច្ចសន្យាលក់ទិញរួមមាន៖ បទបញ្ញត្តិដែលធ្លាប់មាន និងបទបញ្ញត្តិជាធរមាន រួមទាំងឯកសារមួយចំនួនទៀត។

ខ្ញុំបាទ និងនាងខ្ញុំសង្ឃឹមថាសារណានេះ នឹងអាចជួយចូលរួមចំណែកក្នុងការសិក្សាស្រាវជ្រាវសម្រាប់និស្សិតជំនាន់ក្រោយៗ និងការអនុវត្តពាក់ព័ន្ធនឹងកិច្ចសន្យាលក់

ទិញអចលនវត្ថុនៅក្នុងសង្គមខ្មែរជាក់ស្តែង។ ដោយឡែកការចងក្រងសារណានេះប្រាកដជាមានចន្លោះខ្វះខាតជាក់ជាមិនខាន។ ជាមួយគ្នានេះដែរ យើងខ្ញុំសូមអភ័យទោសលើរាល់កំហុសខុសឆ្គងដែលកើតឡើងដោយអចេតនា នូវរាល់ពាក្យពេចន៍ និងខ្លឹមសារដែលមានភាពខុសឆ្គង ឬមិនទាន់គ្រប់គ្រាន់ជាដើម។

ម្យ៉ាងវិញទៀត យើងខ្ញុំទាំងពីរនាក់ សូមអះអាងធានាថាការសរសេរជាសារណានេះ មិនមានការចម្លងពីឯកសារស្នាដៃរបស់បុគ្គលណាមួយឡើយ។

ជាចុងបញ្ចប់ យើងខ្ញុំសូមគោរពជូនពរដល់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ក៏ដូចជាបងប្អូនមិត្តនិស្សិតគ្រប់ជំនាន់ឲ្យមានសុខភាពល្អ សំណាងល្អ ជាពិសេសជួបប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........ ១

**ជំពូក១.ការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុ** ........ ៣

**ផ្នែកទី១. សញ្ញាណនៃគោលការណ៍ស្វ័យភាពនៃឆន្ទៈ** ........ ៣

**ផ្នែកទី២. លក្ខខណ្ឌទូទៅនៃការបង្កើតកិច្ចសន្យា** ........ ៣

កថាខណ្ឌទី១. ការព្រមព្រៀង ........ ៤

កថាខណ្ឌទី២. សមត្ថភាព ........ ៧

កថាខណ្ឌទី៣. កម្មវត្ថុ ........ ១០

កថាខណ្ឌទី៤. តម្លៃតបស្នង ........ ១៣

កថាខណ្ឌទី៥. ទម្រង់នៃកិច្ចសន្យា ........ ១៤

**ផ្នែកទី៣. លក្ខខណ្ឌដោយឡែកនៃកិច្ចសន្យាលក់ទិញអចលនវត្ថុ** ........ ១៤

កថាខណ្ឌទី១. ការពិនិត្យទៅលើឯកសារ ........ ១៤

កថាខណ្ឌទី២. អចលនវត្ថុ ........ ១៦

កថាខណ្ឌទី៣. ថ្លៃលក់ ........ ១៧

កថាខណ្ឌទី៤. ការផ្ទេរកម្មសិទ្ធិ ........ ១៨

**ជំពូក២. អានុភាពនៃកិច្ចសន្យាលក់ទិញអចលនវត្ថុនៅបុរី វិមានស** ........ ១៩

**ផ្នែកទី១. កាតព្វកិច្ចរបស់អ្នកលក់** ........ ១៩

កថាខណ្ឌទី១. កាតព្វកិច្ចចំបងរបស់អ្នកលក់ ........ ១៩

១. កាតព្វកិច្ចផ្ទេរកម្មសិទ្ធិ ........ ១៩

២. កាតព្វកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ ........ ២០

កថាខណ្ឌទី២. កាតព្វកិច្ចផ្សេងៗទៀត ..................................................................២១
១. កាតព្វកិច្ចពន្យល់ ..................................................................................២១
២. កាតព្វកិច្ចធានា .....................................................................................២២
**ផ្នែកទី២. កាតព្វកិច្ចរបស់អ្នកទិញ** ..............................................................២៣
កថាខណ្ឌទី១. កាតព្វកិច្ចចម្បងរបស់អ្នកទិញ .........................................................២៣
១. កាតព្វកិច្ចបង់ថ្លៃទិញ ...............................................................................២៣
២. កាតព្វកិច្ចទទួលវត្ថុ ...............................................................................២៦
កថាខណ្ឌទី២. ពេលវាលាបង់ប្រាក់ ..................................................................២៦
កថាខណ្ឌទី៣. ទីកន្លែងបង់ប្រាក់ ..................................................................២៧
កថាខណ្ឌទី៤. ការបំពានកាតព្វកិច្ចរបស់អ្នកទិញដែលមិនបានបង់ប្រាក់ .....២៧
**សេចក្តីសន្និដ្ឋាន** ...................................................................................៣០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

សេដ្ឋកិច្ចនៅប្រទេសកម្ពុជា ត្រូវបានអនុវត្តតាមរបបសេដ្ឋកិច្ចទីផ្សាសេរី ដូច្នេះហើយប្រជាពលរដ្ឋមានសិទ្ធិក្នុងការធ្វើអាជីវកម្ម ព្រមទាំងមានសេរីភាពពេញលេញក្នុងការបង្កើតកិច្ចសន្យា។ ជាក់ស្តែង សិទ្ធិទាំងអស់នេះមានគ្រប់គ្នា និងស្មើភាពគ្នាដោយមិនប្រកាន់នូវវណ្ណៈពូជសាសន៍ ឬសាសនាឡើយ។ ពោលគឺ មនុស្សម្នាក់ៗអាចធ្វើកិច្ចសន្យាគ្រប់យ៉ាងបានទៅតាមសេចក្តីត្រូវការរបស់ខ្លួន កុំឲ្យតែប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម។ ជាការពិតណាស់ ការគោរពច្បាប់ដោយខ្ជាប់ខ្ជួនរបស់ប្រជាពលរដ្ឋតាមរយៈការគោរពសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនជួយជម្រុញដល់ការគ្រប់គ្រងលើគ្រប់វិស័យដើម្បីឈានឆ្ពោះទៅដល់ការអភិវឌ្ឍប្រទេសមួយឲ្យកាន់តែប្រសើរ។ លើសពីនេះទៅទៀតវិស័យសេដ្ឋកិច្ច ជាវិស័យដ៏មានសក្តានុពលមួយដែលមិនអាចកាត់ផ្តាច់បាន ក្នុងការជួយជម្រុញប្រទេសជាតិឈានទៅរកការអភិវឌ្ឍ។ ម្យ៉ាងវិញទៀត កិច្ចសន្យាក៏ជាយន្តការមួយដែលរួមចំណែក ក្នុងវិស័យសេដ្ឋកិច្ចតាម រយៈចំណាងគតិយុត្តនៃឆន្ទៈគូភាគីនៃកិច្ចសន្យាពិតជាប្រាថ្នានូវអត្ថប្រយោជន៍ ដែលកើតចេញពីកិច្ចសន្យាដូចជាៈ ការលក់ទិញអចលនវត្ថុសម្រាប់រស់នៅ សម្រាប់ប្រកបអាជីវកម្ម ឬក្នុងគោលបំណងផ្សេងៗទៀត។

យ៉ាងណាមិញ គេសង្កេតឃើញមានវត្តមាននៃការលក់ដូរ ផ្ទះល្វែង វីឡា ឬខុនដូរមានជាបន្តបន្ទាប់។ ជាក់ស្តែង តម្រូវការក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែមានការបោះជំហានទៅរកការរស់នៅមួយដែលមានផាសុខភាព និងសោភ័ណ្ឌភាព។ ទន្ទឹមនឹងនេះ បុរី វិមានស ក៏មានការធ្វើអាជីវកម្មលក់ទិញអចលនវត្ថុដូចជា ប្រភេទ វីឡាឃ្វីន វិឡាភ្លោះ និងវីឡាកូនកាត់ដែលមានអាសយដ្ឋានតាមបណ្តោយផ្លូវជាតិលេខ១ ភូមិបឹងឈូកសង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ មុននឹងធ្វើការបកស្រាយនូវកិច្ចសន្យាលក់

ទិញអចលនវត្ថុវាក្យសព្ទមួយចំនួនត្រូវបានលើកយកមកពន្យល់។ ពាក្យ"កិច្ចសន្យា" សំដៅទៅលើបុគ្គលពីរនាក់ឬច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែឬរំលត់កាតព្វកិច្ច។ រីឯ "អចលនវត្ថុ" គឺជាដីធ្លី និងវត្ថុដែលជាប់នឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន។ "កាតព្វកិច្ច" គឺជាចំណងតាមផ្លូវច្បាប់ដែលចង់បុគ្គលពីរនាក់ដែលឲ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថា កូនបំណុល មានករណីយកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀតដែលបានកំណត់ហៅថាម្ចាស់បំណុល។

ដើម្បីធ្វើការអធិប្បាយទៅលើប្រធានបទ កិច្ចសន្យាលក់ទិញអចលនវត្ថុនៅបុរី វិមានស ការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុ ត្រូវបានពន្យល់ក្នុង(ជំពូកទី១) អានុភាពនៃកិច្ចសន្យាលក់ទិញអចលនវត្ថុនៅបុរី វិមានស ត្រូវបានបង្ហាញក្នុង(ជំពូកទី២)។

# ជំពូក១

# ការបង្កើតកិច្ចសន្យាលក់ទិញ

# អចលនវត្ថុ

# ជំពូក១ ការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុ

ជាធម្មតាមុននឹងឈានដល់ការបង្កើតកិច្ចសន្យាលក់ទិញ យើងត្រូវយល់នូវនិយមន័យនៃកិច្ចសន្យាលក់ទិញជាមុនសិន។ មាត្រា៥១៥នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នីតិនិពន្ធបានផ្តោតទៅលើកិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាមួយដែលភាគីម្ខាងហៅថាអ្នកលក់មានករណីយកិច្ចផ្ទេរកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀត ហៅថាអ្នកទិញហើយ អ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់។ ដោយផ្អែកលើមាត្រាខាងលើនេះអ្នកលក់ និងអ្នកទិញមានករណីយកិច្ចចំពោះគ្នាទៅវិញទៅមក ហើយចំពោះ អ្នកលក់មិនត្រឹមតែមានករណីយកិច្ចផ្ទេរសិទ្ធិប៉ុណ្ណោះទេ គឺត្រូវមានសិទ្ធិផ្សេងលើទ្រព្យសម្បត្តិទៅឲ្យអ្នកទិញ។ ជាក់ស្តែង កិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាមួយប្រភេទដែលត្រូវបានបញ្ញត្តក្នុងក្រមរដ្ឋប្បវេណី នៅគន្ថីទី៥ ជំពូកទី១។ ចំពោះ កិច្ចសន្យាលក់ទិញអាចបង្កើតឡើងបានដោយមានការព្រមព្រៀងរវាងគូភាគីទាំងសងខាង និងត្រូវធ្វើជាលិខិតយថាភូត។ ដើម្បីស្វែងយល់អំពីសញ្ញាណ នៃគោលការណ៍ស្វ័យភាពនៃឆន្ទៈយកមកបកស្រាយក្នុង(ផ្នែកទី១)លក្ខខណ្ឌទូទៅនៃការបង្កើត កិច្ចសន្យាលើកមកបង្ហាញក្នុង (ផ្នែកទី២) និងលក្ខខណ្ឌដោយឡែកនៃការលក់ទិញអចលនវត្ថុ ត្រូវបានរៀបរាប់ក្នុង(ផ្នែកទី៣)។

## ផ្នែកទី ១ សញ្ញាណនៃគោលការណ៍ស្វ័យភាពនៃឆន្ទៈ

គោលការណ៍ស្វ័យភាពខាងឆន្ទៈ គឺជាគោលការណ៍មួយដែលឆន្ទៈរបស់បុគ្គល ត្រូវបានយកមកធ្វើជាវិធានច្បាប់។ ការយកឆន្ទៈជាធំនេះ ក៏មានចែងក្នុងក្រមរដ្ឋប្បវេណីមាត្រា ៣ ស្តីពីគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនបានបញ្ជាក់ថាក្រមនេះ គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គលនិងបញ្ញត្តអំពី ទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជនដោយរួមបញ្ចូលទាំងនីតិបុគ្គលផងដែរ។

## ផ្នែកទី២ លក្ខខណ្ឌទូទៅនៃការបង្កើតកិច្ចសន្យា

សកម្មភាពលក់ទិញ គឺជាកិច្ចសន្យាដែលបុគ្គលម្នាក់មានករណីយកិច្ចផ្ទេរកម្មសិទ្ធិនៃវត្ថុមួយ ឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យបុគ្គលម្ខាងទៀត ដែលមានករណីយកិច្ចត្រូវប្រគល់ថ្លៃប្រាក់ឬសិទ្ធិនោះមកវិញ។[១] ដើម្បី ឲ្យកិច្ចសន្យាលក់ទិញមានសុពលភាពទៅបានត្រូវតែមាន ការព្រមព្រៀង(កថាខណ្ឌទី១) សមត្ថភាព(កថាខណ្ឌទី២) និងកម្មវត្ថុ (កថាខណ្ឌទី៣)។

### កថាខណ្ឌទី១ ការព្រមព្រៀង

កិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើតឡើងដោយការព្រមព្រៀងគ្នារវាងគូភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តពិសេសក្នុងច្បាប់។[២] ការព្រមព្រៀង គឺជាការសម្តែងឆន្ទៈរបស់ភាគីនីមួយៗក្នុងកិច្ចសន្យា ដើម្បីបង្ហាញនូវគោលបំណងដ៏ពិតប្រាកដក្នុងការបង្កើតកិច្ចសន្យាអ្វីមួយនោះ។ ទាំងអ្នកលក់ទាំងអ្នកទិញត្រូវមានការព្រមព្រៀងគ្នាដោយពិតប្រាកដ ពោលគឺមិនមានវិការៈនៃការព្រមព្រៀងឡើយដូចជា ការភាន់ច្រឡំ ការឆបោក ការផ្តល់ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព ការគម្រាមកំហែង អំពើកេងយកចំណេញហួសហេតុ បបនីយផ្លូវចិត្ត ការបង្ហាញឆន្ទៈមិនពិតជាដើម។ ហើយប្រសិនបើមានវិការៈនៃការព្រមព្រៀងនោះនឹងនាំឲ្យកិច្ចសន្យាលក់ទិញត្រូវបានលុបចោលតាមអំពើដែលបានប្រព្រឹត្តនោះ។ ដូច្នេះ កិច្ចសន្យាលក់ទិញត្រូវកើតចេញពីការព្រមព្រៀង។ គ្មាននរណាម្នាក់ត្រូវបានគេបង្ខំឲ្យទិញឬឲ្យលក់វត្ថុណាមួយនោះទេ។

កិច្ចសន្យាលក់ទិញ ត្រូវបានបង្កើតឡើងតាមរយៈការព្រមព្រៀងរបស់អ្នកលក់និងអ្នកទិញ។ ជាគោលការណ៍ កិច្ចសន្យាលក់ទិញត្រូវបានដាក់ចូលជាធរមានបន្ទាប់ពីផុតរយៈពេលដែលច្បាប់តម្រូវ ហើយរយៈពេលនេះអាចជារយៈពេលសម្រាប់ការពិចារណា ឬរយៈ

[១] មាត្រា ៥១៥ នៃក្រមរដ្ឋប្បវេណី , លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[២] មាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ពេលនៃការដកការព្រមព្រៀង ដូចជាការលក់ទិញដែលមានលក្ខខណ្ឌ ការលក់ទិញដែលកំណត់អំឡុងពេល និងការលក់ទិញដែលត្រូវបង់ប្រាក់កក់ជាដើម។

### ១. សំណើ

សំណើ គឺជាការស្នើសុំឲ្យបង្កើតកិច្ចសន្យាមួយទៅរកបុគ្គលម្នាក់ទៀតយ៉ាងច្បាស់លាស់ដែលគេហៅថាអ្នកស្នើ។ សំណើមានអានុភាព នៅពេលដែលសំណើបានទៅដល់ភាគីម្ខាងទៀត[៣]និងមានការយល់ព្រមយ៉ាងពិតប្រាកដពីអ្នកទទួលសំណើក្នុងគោលបំណងបង្កើតកាតព្វកិច្ចនៅក្នុងកិច្ចសន្យា។ អ្នកដែលទទួលសំណើអាចប្រគល់សិទ្ធិអំណាចរបស់ខ្លួនទៅឲ្យអ្នកផ្សេងដើម្បីធ្វើសំណើ ឬទទួលសំណើជួសមុខឲ្យខ្លួនបាន។

សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្វីការ[៤] ប្រសិនបើហួសរយៈពេលដែលបានកំណត់នៅក្នុងសំណើនោះសំណើត្រូវបានរលត់។ អំឡុងពេលសម្រាប់ស្វីការត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ។ ប៉ុន្តែ ក្នុងអំឡុងពេលដែលធ្វើសំណើស្វីការមិនអាចដកវិញបានទេ។ ផ្ទុយទៅវិញ ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្វីការក្នុងពេលធ្វើស្វីការ សំណើនោះត្រូវបាត់បង់ដោយស្វ័យប្រវត្តិនៅពេលសំណើហួសរយៈពេលដែលបានកំណត់។

សំណើដែលមិនកំណត់អំឡុងពេលសម្រាប់ស្វីការ គឺជាសំណើដែលធ្វើឡើងដោយមិនបានកំណត់អំពីរយៈពេលសម្រាប់ធ្វើស្វីការរវាងគូភាគី។ ការមិនកំណត់អំឡុងពេលសម្រាប់ស្វីការ គឺស្ថិតនៅក្នុងស្ថានភាពដែលកំពុងនិយាយគ្នាដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើ ភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេសំណើនោះត្រូវបាត់បង់អានុ

[៣] មាត្រា ៣៣៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
[៤] មាត្រា៣៣៨ នៃក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ភាព[៥]។ សំណើដែលធ្វើឡើងដោយបានកំណត់អំឡុងពេលសម្រាប់ស្វីការ និងសំណើដែលមិនកំណត់អំឡុងពេលសម្រាប់ស្វីការវាមានអានុភាពដូចគ្នា ក៏ប៉ុន្តែវាខុសគ្នានៅត្រង់បញ្ចប់អានុភាពទៅវិញ។ សំណើដែលកំណត់អំឡុងពេលសម្រាប់ស្វីការត្រូវអស់អានុភាព នៅពេលដែលសំណើនោះផុតអំឡុងពេល។ ចំណែកសំណើដែលមិនបានកំណត់អំឡុងពេលសម្រាប់ធ្វើស្វីការ គឺអានុភាពបាត់បង់ នៅពេលដែលមានសំណើថ្មីមួយទៀតដែលបញ្ជាក់ពីការអស់អានុភាពនៃសំណើ។

## ២. ស្វីការ

ស្វីការ គឺជាការយល់ព្រមទៅនឹងសំណើមួយ។ ស្វីការអាចបង្កើតកិច្ចសន្យានៅពេលដែលដំណឹងអំពីស្វីការបានមកដល់អ្នកស្នើ។ ស្វីការអាចមានទម្រង់ពីរយ៉ាងដូចសំណើដែរពោលគឺដោយជាក់លាក់ និងដោយតុណ្ហីភាព។ ដើម្បីឲ្យស្វីការមួយអាចបង្កើតជាកិច្ចសន្យាបានត្រូវមានលក្ខណៈមួយចំនួនដូចជា:

ស្វីការត្រូវមានលក្ខណៈពេញលេញ មានន័យថាស្វីការមិនត្រូវមានលក្ខខណ្ឌលើស ឬ បន្ថែមការកែប្រែផ្សេងៗលើសំណើទេ។ ស្វីការត្រូវឆ្លើយតបទាំងស្រុងទៅនឹងសំណើដើម។ ស្វីការត្រូវមានលក្ខណៈច្បាស់លាស់មានន័យថា ស្វីការត្រូវតែស្តែងចេញពីឆន្ទៈពិតប្រាកដរបស់អ្នកទទួលសំណើ ។

## ៣. អានុភាពនៃសំណើ និងស្វីការ

កិច្ចសន្យាកើតឡើងនៅពេលដែលដំណឹងអំពីស្វីការបានមកដល់អ្នកស្នើ។[៦] ស្វីការនៃសំណើមានសុពលភាពលុះត្រាតែ ស្វីការនោះធ្វើឡើងដោយអ្នកទទួលសំណើ។[៧] ស្វីការនិងសំណើត្រូវតែមានខចែងត្រូវគ្នា ហើយប្រសិនបើមានការកែប្រែសំណើក៏ដោយឲ្យតែមិន

---

[៥] មាត្រា នីតិរដ្ឋប្បវេណីរបស់សាស្ត្រាចារ្យ ខាំ សុមករា បោះពុម្ពលើកទី ២ ឆ្នាំ ២០១២ ទំព័រ៣៥

[៦]មាត្រា៣៥០ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[៧]មាត្រា៣៣៧ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

បណ្តាលឲ្យមានការកែប្រែដកមូលដ្ឋាននៃសំណើនោះត្រូវចាត់ទុកថា ជាស្ទីការក្នុងករណីដែលអ្នកធ្វើសំណើមិនមានការតវ៉ាភ្លាមៗនោះ។ តាមច្បាប់កិច្ចសន្យាលក់ទិញអចលនវត្ថុនៅ បុរី វិមានស វាអាចកើតមានឡើងនៅពេលដែលស្ទីការបានបញ្ជូនដល់ដៃអ្នកស្នើ។

### កថាខណ្ឌទី២ សមត្ថភាព

រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយអាចធ្វើការលក់ទិញបានផងដែរ លើកលែងតែក្នុងករណីដែលច្បាប់ហាមឃាម។[៥] យ៉ាងណាមិញ ជនទាំងអស់នោះ ទោះបីជារូបវន្តបុគ្គលក្តីឬនិតិបុគ្គលក្តី ឬជនបរទេសក៏ដោយ ក៏អាចបង្កើតកិច្ចសន្យាលក់ទិញក្នុងនាមជាអ្នកលក់ឬអ្នកទិញបាន។

យ៉ាងណាមិញ ការលក់ទិញអចលនវត្ថុនៅបុរី វិមានស សមត្ថភាពដូចជា: សមត្ថភាពអ្នកលក់ និងសមត្ថភាពអ្នកទិញ។

#### ១. សមត្ថភាពអ្នកលក់

ជាទូទៅ អ្នកលក់ត្រូវតែជាម្ចាស់កម្មសិទ្ធិនៃវត្ថុដែលត្រូវលក់ហើយក៏ត្រូវតែជាមនុស្សដែលមានសមត្ថភាពធ្វើកិច្ចសន្យាលក់។ ដើម្បីលក់វត្ថុណាមួយ អ្នកលក់ត្រូវមានសមត្ថភាពចុះកិច្ចសន្យាលក់ទិញនោះ ពោលគឺអ្នកលក់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពពេញលេញ។ ចំពោះពាក្យថា សមត្ថភាពក្នុងកិច្ចសន្យាសំដៅទៅលើជនទាំងឡាយដែលមានអាយុ១៨ឆ្នាំ ហើយមិនទទួលរងនូវគំហាត់សិទ្ធិ។[៦] ដើម្បីឲ្យជននោះមានសមត្ថភាពពេញលេញក្នុងការធ្វើសកម្មភាពបានត្រឹមត្រូវតាមច្បាប់នោះគឺ ទាល់តែបុគ្គលនោះមិនត្រូវបានកម្រិតសមត្ថភាពតាមច្បាប់ក្នុងការធ្វើសកម្មភាពរបស់ខ្លួនឡើយ។ តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៦ មានការធ្វើកម្រិតសមត្ថភាពជនដែលមិនអាចធ្វើសកម្ម

---

[៥] មាត្រា ៥២៤ នៃក្រមរដ្ឋប្បវេណីលេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[៦] សំដៅទៅលើ អនីតិជន និងនីតិជនគំហាត់សិទ្ធិ ដូចជាមនុស្សវិបល្លាសស្មារតី(វិកលចារឹក)

ភាពបានមានដូចជា៖ អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមរបបហិតូបត្ថម្ភជាដើម។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៦ បានកម្រិតសមត្ថភាពជនដែលមិនអាចធ្វើសកម្មភាពបានដូចជា: អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមរបបហិតូបត្ថមជាដើម។

អនីតិជន គឺជាជនដែលមានអាយុក្រោម ១៨ឆ្នាំ ហើយគ្មានសមត្ថភាពក្នុងការធ្វើអ្វីមួយតាមផ្លូវច្បាប់។[១០] ម៉្យាងវិញទៀតអនីតិជនក៏អាចមានសមត្ថភាពចំពោះច្បាប់ដែរដូចជា: ការចុះកិច្ចសន្យាដោយមានការយល់ព្រមពីអាណាព្យាបាល និងសកម្មភាពប្រចាំថ្ងៃរបស់ខ្លួនដូចជា ទិញចំណីអាហារ សម្ភារៈសិក្សា ឬសម្លៀកបំពាក់ផ្ទាល់ខ្លួន។

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។ ជាជនដែលឆ្កួតវង្វេង ល្ងីល្ងើ ជនដែលធ្លាក់ក្នុងស្ថានភាពជាមនុស្សរុក្ខជាតិ និងជាជនដែលត្រូវដកសិទ្ធិគ្រប់គ្រងទ្រព្យរបស់ខ្លួន ដោយសាក្រមតុលាការ។ តុលាការអាចប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅបានតាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួត ពិនិត្យអ្នកអាណាព្យាបាលសម្រាប់ អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬជាចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យាការ។[១១] ជាកាពិតជននៅក្រោមអាណាព្យាបាលទូទៅមិនអាចធ្វើសកម្មភាពគតិយុត្តដោយឯករាជ្យបានទេ គឺត្រូវផ្ទេរឲ្យអ្នកតំណាងដែលច្បាប់បានកំណត់។ ហើយប្រសិនបើអនុវត្តផ្ទុយពីគោលការណ៍នេះ សកម្មភាពដែល

[១០] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីលេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[១១]មាត្រា២៤ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

បានអនុវត្តដោយជននៅក្រោមអាណាព្យាបាលទូទៅ អាចត្រូវបានលុបចោលបានផលដែរ។មានន័យថា ចំពោះសកម្មភាពដែលបានធ្វើឡើងដោយអ្នកនៅក្រោមអាណាព្យាបាលទូទៅដោយផ្ទាល់ លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ មិនអាចលុបចោលបានទេ។[១២] សកម្មភាពដែលបានធ្វើដោយអ្នកនៅក្រោមអាណាព្យាបាលទូទៅដោយមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅ ក៏អាចលុបចោលបានដែរ។

ចំពោះជននៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹងនិងវិនិច្ឆ័យដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។[១៣] ជាជនដែលចាយវាយខ្ជះខ្ជាយហួសហេតុ ឬជនដែលមានសតិទន់ខ្សោយដោយជម្ងឺ គ ថ្លង់ ខ្វិន ជរា ប្រមឹក សេពគ្រឿងញៀន។ ហើយជាជនដែលតុលាការបានសម្រេចប្រកាសចាប់ផ្តើមជំនួយចំពោះជននោះ ទៅតាមពាក្យសុំរបស់បុគ្គលជាកំណត់។ ព្រោះថាជននៅក្រោមហិតូបត្ថម្ភអាចធ្វើសកម្មភាពដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ ដែលសកម្មភាពទាំងនោះទាក់ទងនឹងជីវភាពប្រចាំថ្ងៃ។ លើកលែងតែ សកម្មភាពមួយចំនួនដែលបានកំណត់ក្នុងមាត្រា៣០ នៃក្រមរដ្ឋប្បវេណី ក្នុងការចុះកិច្ចសន្យាសំខាន់ៗទាំងនោះជាពិសេសក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុក៏ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈបើមិនដូច្នេះទេ កិច្ចសន្យានោះអាចលុបចោលបាន។ ជារួមហិតូបត្ថម្ភ ជាគោលការណ៍អាចធ្វើសកម្មភាពគតិយុត្តដោយឯករាជ្យបានក៏ប៉ុន្តែ ជាករណីលើកលែងចំពោះសកម្មភាពសំខាន់ៗ ចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈដូចមានចែងក្នុងមាត្រា ៣០ នៃក្រមរដ្ឋប្បវេណី។ ប្រសិនបើការអនុវត្តផ្ទុយពីនេះ សកម្មភាពដែលជននៅក្រោមរបប ហិតូបត្ថម្ភបានធ្វើដោយមិនមានការយល់ព្រមពីហិតូបត្ថម្ភកៈ អាចត្រូវបានលុបចោល។

---

[១២]មាត្រា២៦ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[១៣]មាត្រា២៨ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ចំពោះ អនីតិជនដែលមានអត្តាធីនភាពមានសមត្ថភាពពេញលេញក្នុងការចុះកិច្ចសន្យាដូចនីតិជនដែរ។[១៤]

### ២. សមត្ថភាពអ្នកទិញ

សមត្ថភាពរបស់អ្នកទិញ មានលក្ខណៈដូចគ្នានិងសមត្ថភាពរបស់អ្នកលក់ដែរតែអ្វីដែលមានលក្ខណៈប្លែកនោះ គឺច្បាប់បានធ្វើការហាមឃាត់នៅនឹងបុគ្គលមួយចំនួនតាមផ្លូវច្បាប់មិនឲ្យធ្វើសកម្មភាពក្នុងការទិញ ដើម្បីជៀសវាងការបាត់បង់តម្លៃនៅក្នុងការទិញ។ ហើយបុគ្គលដែលច្បាប់បានហាមឃាតមិនឲ្យធ្វើសកម្មភាពទិញនោះមានដូចជា:

- អ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមផ្លូវច្បាប់តាមផ្លូវតុលាការ តាមកិច្ចសន្យា ពោលគឺអាណាព្យាបាលហិតូបត្ថម្ភ។
- អ្នកទិញដោយការលក់ដោយបង្ខំនូវទ្រព្យសម្បត្តិ ដែលខ្លួនបានទទួលភារកិច្ចលក់ដោយផ្ទាល់ខ្លួន ឬតាមរយៈអន្តរការីជាដើម។
- មន្ត្រីរាជការដែលទទួលបន្ទុកចាត់ការលក់ដោយបង្ខំ ឬទទួលបន្ទុកគ្រប់គ្រងការលក់ដោយបង្ខំ។
- ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ឬមន្ត្រីតុលាការដែលកំពុងចាត់ការនៅតុលាការដែលខ្លួនបំពេញភារកិច្ចនោះ។
- មេធាវី ឬសាការី ដែលទាក់ទងនឹងរឿងក្តីដែលខ្លួនទទួលបន្ទុក និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គអវត្តមានជាដើម។[១៥]

### កថាខណ្ឌទី៣ កម្មវត្ថុ

កម្មវត្ថុនៃកិច្ចសន្យា គឺជាលក្ខខណ្ឌមួយដើម្បីឲ្យកិច្ចសន្យាលក់ទិញអចលនវត្ថុមានសុពលភាព។ នៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុនៅបុរី វិមានស កម្មវត្ថុនៃកិច្ចសន្យា

---

[១៤] មាត្រា២២ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[១៥] មាត្រា ៥២៥ និង ៥២៦ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

មានតែអចលនវត្ថុតែប៉ុណ្ណោះ។ ចំពោះអចលនវត្ថុទាំងនោះមានដូចជា ដីធ្លី និងវត្ថុដែលជាប់ទៅនឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាននោះទេ ដូចជា អាគារ ដំណាំ រុក្ខជាតិជាអាទ៏។[16] ការលក់ទិញនឹងអាចអនុវត្តបានលុះត្រាតែមានវត្ថុមួយជាក់លាក់អាចធ្វើកើត អាចបែងចែកដោយឡែកពីគ្នាតាមប្រភេទ(តាមបរិមាណនិងតាមគុណភាព) និងតាមស្របច្បាប់ និងរបៀបរៀបរយសាធារណៈឬទំនៀមទម្លាប់ដ៏ល្អ។

## ១. កម្មវត្ថុដែលមាននាពេលបច្ចុប្បន្ន

ចំពោះ កម្មវត្ថុនៃកិច្ចសន្យាលក់ទិញអចលនវត្ថុនៅបុរី វិមានស អាចមានកម្មវត្ថុនាពេលបច្ចុប្បន្ន និងកម្មវត្ថុនាពេលអនាគត។

វត្ថុដែលមាននាពេលបច្ចុប្បន្ន គឺជាវត្ថុដែលមានពិតប្រាកដនាពេលបច្ចុប្បន្ន ដូចជាផ្ទះដែលសាងសង់ហើយ។ ហើយនៅពេលដែលមានកិច្ចសន្យាលក់ទិញផ្ទះស្របនោះ អ្នកលក់នឹងធ្វើការផ្ទេរកម្មសិទ្ធិទាំងមូលទៅឲ្យអ្នកទិញ ហើយអ្នកទិញអាចធ្វើការបង់ប្រាក់តាមការព្រមព្រៀងក្នុងកិច្ចសន្យា។

ឧទាហរណ៍: ពូសុខ បានទិញវិឡាឃ្វីននៅបុរី វិមានស ដោយក្រុមហ៊ុនបានសាងសង់រួចហើយ។ មានន័យថា វីឡានោះបានការសាងសង់រួចរាល់ស្អាតហើយ ទើបមានអតិថិជនមកទិញ។

## ២. កម្មវត្ថុដែលមាននាពេលអនាគត

វត្ថុដែលលក់ ត្រូវមានរូបរាងពិតប្រាកដនាពេលចុះកិច្ចសន្យា។ ម្យ៉ាងទៀតអចលនវត្ថុខ្លះមិនទាន់មានរូបរាងច្បាស់លាស់នៅឡើយ ក៏អាចជាកម្មវត្ថុនៅក្នុងកិច្ចសន្យាលក់ទិញដែរដូចជាវត្ថុដែលមាននាពេលអនាគត។

[16]មាត្រា១២០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

វត្ថុនាពេលអនាគត គឺសំដៅទៅលើអចលនវត្ថុទាំងឡាយ ដែលមិនទាន់មាននៅពេលបច្ចុប្បន្នតែវាប្រាកដនឹងអាចកើតមានឡើងនៅពេលអនាគតយ៉ាងពិតប្រាកដក៏អាចធ្វើជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញបានផងដែរមានន័យថា គូភាគីមានភាពជឿជាក់ថាអចលនវត្ថុនោះ នឹងអាចកើតមានឡើងនៅក្នុងពេលខាងមុខនេះ។ អចលនវត្ថុនេះមានដូចជាគម្រោងសាងសង់ផ្ទះ ដែលមានតែប្លង់នៅឡើយ។ ទោះបីវត្ថុនោះមិនទាន់បានលេចចេញជារូបរាងក៏ដោយពោលគឺ ផ្ទះដែលមានត្រឹមតែប្លង់សាងសង់នោះក៏គេអាចលក់ផ្ទះដែលមិនទាន់សាងសង់នោះបានដែល។ ការលក់ប្រភេទនេះ តម្រូវឲ្យអ្នកលក់សាងសង់សំណង់នៅក្នុងរយៈពេលកំណត់ការផ្ទេរកម្មសិទ្ធិ ការប្រគល់វត្ថុ និងធានានូវការសម្រេចជារូបរាងវត្ថុទៅតាមមកិច្ចសន្យា។ ការផ្ទេរកម្មវត្ថុ និងការប្រគល់ប្រាក់ គឺអាស្រ័យទៅលើប្រភេទនៃកិច្ចសន្យាដែលគូភាគីបានជ្រើសរើស។

- ការលក់ដោយកំណត់ពេលនៅក្នុងកិច្ចសន្យានេះ កម្មសិទ្ធិត្រូវផ្ទេរទៅឲ្យអ្នកទិញនៅពេលវត្ថុនោះសាងសង់រួចជាស្ថាពរ។ ចំពោះ កិច្ចសន្យាលក់ទិញអចលនវត្ថុនៅបុរី វិមានសការសាងសង់នឹងត្រូវបញ្ចប់ជាស្ថាពរក្នុងអំឡុងពេល ១៨ ខែគិតចាប់ពីថ្ងៃព្រមព្រៀងលក់។ ការផ្ទេរកម្មសិទ្ធិធ្វើឡើងតាមលិខិតយថាភូត ហើយវាបង្កើតអានុភាពប្រតិសកម្ម ដោយគិតចាប់ពីថ្ងៃចុះកិច្ចសន្យាលក់បានសេចក្ដីថាអ្នកទិញជាម្ចាស់កម្មសិទ្ធិចាប់ពីថ្ងៃចុះកិច្ចសន្យាលក់ទិញ។ ម្យ៉ាងវិញទៀតអ្នកទិញត្រូវប្រគល់លុយនៅពេលប្រគល់វត្ថុ។

- ការលក់ទៅតាមស្ថានភាពនៃសំណង់ក្នុងកិច្ចសន្យានេះអ្នកលក់ ត្រូវផ្ទេរកម្មសិទ្ធិទៅឲ្យអ្នកទិញនូវសិទ្ធិលើវត្ថុដែលបានសាងសង់បន្តិចម្ដងៗ។ ហើយអ្នកទិញវិញ ត្រូវប្រគល់លុយបន្តិចម្ដងៗទៅតាមការសម្រេចបាននៃស្ថានភាពសំណង់។ឧទាហរណ៍: លោកស្រីធីតា បានទិញវិឡាឃ្វីននៅបុរី វិមានស ដែលក្រុមហ៊ុនទើបតែធ្វើការសាងសង់មិនទាន់រួចរាល់នៅឡើយ។

**កថាខណ្ឌទី៤ តម្លៃតបស្នង**

តម្លៃ គឺជាចំនួនទឹកប្រាក់ដែលអ្នកទិញត្រូវប្រគល់ទៅឲ្យអ្នកលក់ ដើម្បីជាថ្នូរនិងការផ្ទេរកម្មសិទ្ធិនៃអចលនវត្ថុ ដែលជាកម្មវត្ថុនៃការលក់នោះមកឲ្យខ្លួន។ បើកិច្ចសន្យាមួយគ្មានការកំណត់តម្លៃឲ្យបានច្បាស់លាស់នោះនាំឲ្យមិនមានការលក់ទិញនោះទេ។ ជាគោលការណ៍តម្លៃតបស្នងត្រូវតែពិតប្រាកដនិងជាក់លាក់។ ដោយផ្អែកលើតម្លៃតបស្នងនេះយើងអាចកំណត់ពីប្រភពនៃកិច្ចសន្យាបានដូចជា កិច្ចសន្យាដែលមានតាវកាលិកតបវិញ ដែលមិនមែនជាចំនួនទឹកប្រាក់នោះគេមិនអាចកំណត់ថាជាកិច្ចសន្យាលក់បានទេ។តាមទស្សនៈសេដ្ឋកិច្ចតម្លៃតបស្នងផ្តុំឡើងដោយធាតុផ្សំបីយ៉ាងរួមមានដូចជា: តម្លៃវត្ថុ ប្រាក់ចំណេញ និងសោហ៊ុយផ្សេងៗទៀត។

- តម្លៃវត្ថុ នៅក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរីតម្លៃកើតចេញពីច្បាប់នៃការផ្គត់ផ្គង់ និងតម្រូវការ។
- ប្រាក់ចំណេញ នៅក្នុងរបបសេដ្ឋកិច្ចទីផ្សាសេរីប្រាក់ចំណេញជាគុណប្រយោជន៍ដែលជំរុញឲ្យកើតមាននូវសកម្មភាពលក់ទិញ។
- សោហ៊ុយផ្សេងៗទៀត នៅក្នុងកិច្ចសន្យាលក់ទិញភាគីទាំងសងខាងត្រូវចេញស្មើគ្នានូវសោហ៊ុយធ្វើលិខិត ឬសោហ៊ុយផ្សេងៗទៀតដែលត្រូវចំណាយ ក្នុងការធ្វើកិច្ចសន្យាលក់ទិញលើកលែងតែមានការកំណត់ផ្សេងរបស់គូភាគី។[១៧] ឧទាហរណ៍: សោហ៊ុយក្នុងការជួលមេធាវី ធ្វើឯកសារកិច្ចសន្យាលក់ទិញ គឺជាសាហ៊ុយក្នុងការលក់ទិញ។

[១៧] មាត្រា ៥២២ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

### កថាខណ្ឌទី៥ ទម្រង់នៃកិច្ចសន្យា

តាមគោលការណ៍នៃការព្រមព្រៀង បង្ករភាពងាយស្រួល និងឆាប់របហ័សក្នុងការបង្កើតកិច្ចសន្យា។ ប៉ុន្តែទន្ទឹមនឹងនេះ បានបង្កនូវផលវិបាកមួយចំនួនផងដែរពាក់ព័ន្ធនិងភស្តុតាង និងការបកស្រាយកិច្ចសន្យានៅពេលដែលមានវិវាទកើតឡើង។ ជាទូទៅ កិច្ចសន្យាទាំងឡាយអាចត្រូវដាក់ឲ្យអនុវត្តទៅបានទោះបីជាកិច្ចសន្យានោះធ្វើឡើង ជាលិខិតឯកជន ឬជាលិខិតយថាភូតក៏ដោយ។ ប៉ុន្តែ មានកិច្ចសន្យាមួយចំនួនដែលច្បាប់បានត្រូវឲ្យធ្វើជាទម្រង់លាយលក្ខណ៍អក្សរទើបមានសុពលភាពគតិយុត្ត ដូចជាកិច្ចសន្យាលក់ទិញអចលនវត្ថុគឺត្រូវតែធ្វើជាលិខិតយថាភូត។

#### ១. លិខិតយថាភូត

លិខិយថាភូត ជាលិខិតដែលធ្វើឡើងតាមរូបមន្តច្បាប់ដោយមន្ត្រីសាធារណៈដែលមានសមត្ថកិច្ចក្នុងគោលបំណងដើម្បីផ្ទេរកម្មសិទ្ធិនៃអចលវត្ថុទៅឲ្យបុគ្គលផ្សេងទៀត។ តាមន័យចង្អៀត គឺជាលិខិតទាំងឡាយដែលរៀបចំឡើងដោយសាការី។

#### ២. លិខិតឯកជន

លិខិតឯកជន ជាលិខិតដែលធ្វើឡើងដោយបុគ្គលឯកជន និងបុគ្គលឯកជនឥតមានមន្ត្រីរាជការសាធារណៈណាមួយជួយដឹងឮនឹងឃើញនោះទេ គឺមានតែហត្ថលេខា ឬស្នាមមេដៃនៃ គូភាគីតែប៉ុណ្ណោះ។ ទោះបីជាលិខិតនេះ បានធ្វើឡើងដោយបុគ្គលឯកជន និងបុគ្គលឯកជនក៏ដោយក៏កិច្ចសន្យានេះមានសុពលភាពដូចគ្នាទៅ និងលិខិតយថាភូតផងដែរ។

## ផ្នែកទី៣ លក្ខខណ្ឌដោយឡែកនៃកិច្ចសន្យាលក់ទិញអចលនវត្ថុ

### កថាខណ្ឌទី១ ការពិនិត្យទៅលើឯកសារ

មុននឹងធ្វើការទិញអចលនវត្ថុនៅបុរី អ្នកទិញគួរតែពិនិត្យទៅលើឯកសារចំនួន៥ដូចជា: ប្លង់រឹង លិខិតចុះបញ្ជីក្រុមហ៊ុន ផែនការមេ អាជ្ញាប័ណ្ណសាងសង់ និងអាជ្ញាប័ណ្ណបុរី។

"ប្លង់រឹង" អ្នកត្រូវប្រាកដថាម្ចាស់គម្រោងមានសិទ្ធិកាន់កាប់ស្របច្បាប់ទៅលើគម្រោងអភិវឌ្ឍន៍នេះ ហើយគម្រោងបុរីដែលអ្នកមានបំណងទិញត្រូវមានប្លង់រឹងមេមួយដែលត្រូវធ្វើការបែងចែកប្លង់រឹងទៅឲ្យម្ចាស់ផ្ទះនីមួយៗជាចាំបាច់។ ឯកសារខាងលើវាពិតជាចំណុចចាំបាច់ត្រូវយល់ដឹងដើម្បីកុំឲ្យមានការខាតបង់ថវិការជាយថាហេតុ នៅពេលអ្នកទិញគម្រោងបុរីណាមួយ។

"លិខិតចុះបញ្ជីក្រុមហ៊ុន" សម្រាប់ក្រុមហ៊ុនអភិវឌ្ឍន៍ទាំងអស់ត្រូវមកចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដើម្បីទទួលសិទ្ធិក្នុងការប្រកបរបរអាជីវកម្មនេះជាកាតព្វកិច្ចដែលក្រុមហ៊ុនអភិវឌ្ឍន៍ត្រូវតែបំពេញជាចាំបាច់។

"ផែនការមេ" ផែនការមេរបស់គម្រោងបុរី គឺជាប្លង់មេដ៏សំខាន់របស់គម្រោងប្លង់មេនឹងអាចប្រាប់ថាតើគម្រោងមានហេដ្ឋារចនាសម្ព័ន្ធដូចម្តេច? មានប្លង់លំនៅដ្ឋានដូចម្តេច? មិនត្រឹមតែប៉ុណ្ណោះមុននឹង ផ្តល់អាជ្ញាប័ណ្ណសាងសង់ទៅឲ្យគម្រោងអភិវឌ្ឍន៍ណាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានតម្រូវឲ្យម្ចាស់គម្រោងធ្វើបទបង្ហាញពីផែនការមេច្បាស់លាស់ជាមុនសិន។ ការអភិវឌ្ឍន៍ទាំងអស់ត្រូវគោរពតាមគោលការណ៍នៃការផែនការមេសម្រាប់អភិវឌ្ឍន៍ទីក្រុង និយាយជារួមការមានផែនការមេមួយច្បាស់លាស់ វាពិតជាធ្វើឲ្យគម្រោងបុរីនោះធ្វើឡើងប្រកបដោយស្តង់ដារកាន់តែប្រសើរឡើង។

"អាជ្ញាប័ណ្ណសាងសង់" ក្រៅពីផែនការមេគម្រោងបុរីនោះត្រូវតែមានអាជ្ញាប័ណ្ណសាងសង់ត្រឹមត្រូវដែលចេញដោយក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់។ ដើម្បីទទួលបានអាជ្ញាប័ណ្ណនេះ គម្រោងត្រូវមានផែនការមេមានប្រាក់តម្កល់២%ប្រភពប្រាក់ចំណូលច្បាស់លាស់ដើមទុនមានវត្ថុដាក់ធានាមានប្លង់ និងទ្រព្យផ្សេងៗទៀតដែលជួយគាំទ្រដល់គម្រោងនោះ។

"អាជ្ញាប័ណ្ណបុរី" ឯកសារសំខាន់ដែលអ្នកត្រូវតែត្រួតពិនិត្យផងដែរនោះគឺអាជ្ញាប័ណ្ណបុរី នៅពេលដែលបុរីមានឯកសារនេះហើយបានន័យថាបុរីនេះ ជាបុរីដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច។ ដូច្នេះ ហើយទៅពេលដែលអ្នលទិញបានពិនិត្យទៅលើកត្តាទាំងប្រាំនេះ ហើយនោះអ្នកទិញអាចធ្វើការទិញនូវអចលនវត្ថុនៅបុរីមានសុវត្ថិភាព។

## កថាខណ្ឌទី២ អចលនវត្ថុ

អចលនវត្ថុ សំដៅទៅលើដីធ្លី និងវត្ថុជាប់នៅលើដីហើយមិនអាចផ្លាស់ប្តូរទីកន្លែងបានដូចជាអាគារសំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍។ អចលនវត្ថុ សំដៅទៅលើវត្ថុជាប់នៅលើដីហើយជាវត្ថុដែលតាំងភ្ជាប់យ៉ាងមាំទៅនឹងដីដែលគេចាត់ទុកជាផ្នែកមួយនៃដី។[១៨]
អចលនវត្ថុ គឺជាវត្ថុដែលមានរូប "ដី" និង "អគារ" តែមិនរួមបញ្ចូលវត្ថុទាំងឡាយដែលអាចផ្តាច់ ឬដកចេញមិនបណ្តាលឲ្យខូចខាតដល់ដីនោះទេ។ តាមច្បាប់ភូមិបាល អចលនវត្ថុត្រូវបានបែងចែកជា បីប្រភេទគឺ: អចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ព្វវាសនា នឹងអចលនវត្ថុតាមការកំណត់របស់ច្បាប់។

### ១.អចលនវត្ថុពីកំណើត

អចលនវត្ថុពីកំណើត គឺជាអចលនវត្ថុដែលកើតឡើងដោយឯកឯង។ អចលនវត្ថុពីកំណើត មានដីធម្មជាតិដូចជា ព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ឬមិនអាចដាំដុះ ដីលិចទឹកដោយទឹកនៅនឹង ឬទឹកហូរ និងសំណង់ ឬការរៀបចំទាំងឡាយដែលស្ថិតនៅជាប់ជាមួយ កន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិល ឬផ្លាស់ប្តូរកន្លែងបាន។[១៩]

---

[១៨]មាត្រា១២០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
[១៩]មាត្រា២ កថាខណ្ឌទី២ នៃច្បាប់ភូមិបាល,លេខនស/រកម/០៨-០១/ចុះថ្ងៃទី៣០,សីហា,២០០១។

**២.អចលនវត្ថុពីភ័ព្វវាសនា**

អចលនវត្ថុពីភ័ព្វវាសនា គឺជាវត្ថុដែលជាប់នឹងដីឬការប្រែក្លាយពីចលនវត្ថុ ទៅជាអចលនវត្ថុដោយការបង្កើតវាសម្រាប់ប្រើប្រាស់ជាប់ជាមួយ នឹងអាគារសម្រាប់ការតែងលម្អ ហើយមិនអាចបំបែកចេញបាននាំឲ្យមានការខូចខាត ឬដូរសភាពដើម។[២០] ឧទាហរណ៍ ដើមឈើ កង្ហាលភ្ជាប់ជញ្ជាំង ឬពិដាន អំពូលភ្លើង ទូ តុ ឧបករណ៍តែងលំអរផ្សេងទៀត។

**៣.អចលនវត្ថុតាមការកំណត់របស់ច្បាប់**

អចលនវត្ថុតាមការកំណត់របស់ច្បាប់ គឺជាវត្ថុដែលច្បាប់បានកំណត់ថាជាចលនវត្ថុ ឬអចនវត្ថុ។[២១] គេអាចចាត់ទុកជាអចលនវត្ថុតាមច្បាប់កំណត់បាន លុះត្រាតែវត្ថុដែលច្បាប់កំណត់ឲ្យនៅក្នុងរបៀបជាអចលនវត្ថុពីកំណើត ថ្វីបើវាជាវត្ថុអាចដឹកនាំបាន ហើយត្រូវមានចំណុះ៣០តោនឡើងទៅដូចជា ទូក កប៉ាល់ ផ្ទះ ជាដើម។

**កថាខណ្ឌទី៣ ថ្លៃលក់**

ថ្លៃលក់មានលក្ខណៈចាំបាច់នៅក្នុងកិច្ចសន្យាលក់ទិញ បើពុំមានតម្លៃលក់ទេនោះ គេមិនអាចកំណត់ជាកិច្ចសន្យលក់ទិញបានឡើយ។ ហើយកិច្ចសន្យាលក់ទិញអចលនវត្ថុ តម្លៃត្រូវបានកំណត់ជាទឹកប្រាក់ដែលមានលក្ខណៈជាក់លាក់និងត្រឹមត្រូវ។ តម្លៃនៃវត្ថុពេលខ្លះត្រូវបានគេកំណត់រួចជាស្រេចដូចជា តាមរយៈការចរចាររវាងគូភាគី តាមរយៈអ្នកលក់ដោយពុំចាំបាច់មានការចរចារគ្នា។ ចំពោះ តម្លៃលក់អចលនវត្ថុនៅបុរី វិមានស ក្រុមហ៊ុនបានកំណត់តម្លៃរួចជាស្រេច ដោយពុំចាំបាច់មានការចរចារគ្នា។ ឧទាហរណ៍ៈ វិឡាភ្លោះដែលមានទទឹងផ្ទះ១២.០០ម៉ែត្រ បណ្តោយផ្ទះ១២.២០ម៉ែត្រ ក្រុមហ៊ុនបានលក់ក្នុងតម្លៃ ៣៨០,០០០.០០ (សាមសិបប្រាំបីម៉ឺន)ដុល្លារអាមេរិក។ អចលនវត្ថុត្រូវបានកំណត់តម្លៃលក់

[២០]មាត្រា២ កថាខណ្ឌទី៣ នៃច្បាប់ភូមិបាល,លេខនស/រកម/០៨-០១/ចុះថ្ងៃទី៣០,សីហា,២០០១។
[២១]មាត្រា២ កថាខណ្ឌទី៤ នៃច្បាប់ភូមិបាល,លេខនស/រកម/០៨-០១/ចុះថ្ងៃទី៣០,សីហា,២០០១។

ដោយការឯកភាពគ្នារបស់ភាគី។ ការមិនព្រមព្រៀងគ្នាលើតម្លៃមិនអាចបង្កើតកិច្ចសន្យាលក់បានទេ។

**កថាខណ្ឌទី៤ ការផ្ទេរកម្មសិទ្ធិ**

ជាទូទៅ កិច្ចសន្យាលក់ទិញអចលនវត្ថុគឺត្រូវតែធ្វើការផ្ទេរកម្មសិទ្ធិ ពីអ្នកលក់ទៅអ្នកទិញជាលក្ខខណ្ឌចម្បងមួយសម្រាប់ការលក់។ អាស្រ័យហេតុនេះ បើគ្មានការផ្ទេរកម្មសិទ្ធិទេ នោះវាមិនបង្កើតបានជាការលក់ទិញទេ។ ដូច្នេះ ការផ្ទេកម្មសិទ្ធិនេះវាមានសារៈសំខាន់ណាស់ចំពោះភាគីអ្នកលក់។

# ជំពូក២
# អានុភាពនៃកិច្ចសន្យាលក់ទិញ
# អចលនវត្ថុនៅបុរី វិមានស

## ជំពូកទី ២ អានុភាពនៃកិច្ចសន្យាលក់ទិញអចលនវត្ថុនៅបុរីវិមាន ស

កិច្ចសន្យាលក់ទិញអចលនវត្ថុមានអានុភាពបាន លុះត្រាតែការបង្ហាញឆន្ទៈ របស់បុគ្គលពីរនាក់ឬច្រើននាក់ មានការព្រមព្រៀងគ្នាក្នុងកិច្ចសន្យា។ នោះនឹងនាំឲ្យមានកាតព្វកិច្ចរវាងអ្នកលក់កើតឡើង(ផ្នែកទី១) រួមទាំងកាតព្វកិច្ចអ្នកទិញ(ផ្នែកទី២)ក៏បានកើតឡើងដែរ។ ព្រោះកិច្ចសន្យា គឺជាប្រភពនៃកាតព្វកិច្ច។

### ផ្នែកទី ១ កាតព្វកិច្ចរបស់អ្នកលក់

នៅក្នុងកិច្ចសន្យាលក់ទិញ ភាគីទាំងសងខាងត្រូវមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកព្រោះកិច្ចសន្យាលក់ទិញ ជាកិច្ចសន្យាទ្វេភាគី។ នៅពេលដែលកិច្ចសន្យាមួយកើតមាននោះនាំឲ្យសិទ្ធិនិងកាតព្វកិច្ចរវាងគូភាគីក៏កើតមានដែរ។ មានន័យថា មិនអាចមានសិទ្ធិនិងកាតព្វកិច្ចរវាងគូភាគីកើតមានឡើងឡើយប្រសិនបើគ្មានកិច្ចសន្យានោះទេ។ ដូច្នេះអ្នកលក់មានកាតព្វកិច្ចចម្បង (កថាខណ្ឌទី១) នឹងមានកាតព្វកិច្ចផ្សេងៗទៀតដែលត្រូវបំពេញ(កថាខណ្ឌទី២)។

#### កថាខណ្ឌទី១. កាតព្វកិច្ចចម្បងរបស់អ្នកលក់

កាតព្វកិច្ចចម្បងរបស់អ្នកលក់ គឺជាកាតព្វកិច្ចមួយដែលអ្នកលក់ត្រូវតែបំពេញដោយមិនអាចខ្វះបាននោះទេ។ យ៉ាងណាមិញ បើអ្នកលក់មិនអនុវត្តនូវកាតព្វកិច្ចចម្បងនេះទេនឹងនាំឲ្យមានការរំលាយកិច្ចសន្យាបានផងដែរ។ ហើយកាតព្វកិច្ចនោះមានដូចជា: កាតព្វកិច្ចផ្ទេរកម្មសិទ្ធិ និងកាតព្វកិច្ចប្រគល់វត្ថុ។

##### ១.កាតព្វកិច្ចផ្ទេរកម្មសិទ្ធិ

ការផ្ទេរកម្មសិទ្ធិ សំដៅទៅលើការផ្ទេរសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផលនិងសិទ្ធិចាត់ចែងលើវត្ថុ។ យ៉ាងណាមិញ ទោះបីជាមានការផ្ទេរសិទ្ធិហើយក៏ដោយនៅតែមិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំបានចុះបញ្ជីសិទ្ធិនោះតាមការបញ្ញត្តិនៃច្បាប់ពុំបានចុះបញ្ជីសិទ្ធិនោះ តាមការបញ្ញត្តិនៃច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងដែលទាក់ទងនឹងការចុះ

បញ្ជី។ ដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុបានលុះត្រាតែ ការផ្ទេរកម្មសិទ្ធិនេះមានការព្រមព្រៀងរវាងគូភាគីនិងមានការចុះបញ្ជីឲ្យបានត្រឹមត្រូវតាមបញ្ញត្តិនៃច្បាប់ស្តីពីការចុះបញ្ជី។ ក្នុងន័យនេះ មានន័យថាការផ្ទេរកម្មសិទ្ធិកើតមានឡើងនៅពេលដែលអចលនវត្ថុត្រូវបានចុះបញ្ជី ហើយអ្នកទិញអាចក្លាយទៅជាកម្មសិទ្ធិករនៃអចលនវត្ថុត្រឹមត្រូវស្របច្បាប់បាន។

នៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុនៅបុរី វិមានស អ្នកលក់ត្រូវមានកាតព្វកិច្ចផ្ទេរកម្មសិទ្ធិលើទ្រព្យសម្បត្តិដែលបានលក់ និងប្រគល់លិខិតផ្សេងៗដែលចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ ទៅឲ្យអ្នកទិញតាមការព្រមពៀងនៅក្នុងកិច្ចសន្យា។[២២] ចំណែកឯមាត្រា ៥៣១នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្ត *អ្នកលក់ត្រូវមានករណីយកិច្ចត្រូវផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទិញទៅឲ្យអ្នកទិញ*។

ឧទាហរណ៍: លោកA បានលក់វិឡាភ្លោះ ទៅឲ្យអ្នកទិញB ក្នុងតម្លៃ៣០០,០០០(សាមសិបម៉ឺន) ដុល្លារអាមេរិក ដូច្នេះ លោកA ត្រូវតែមាននូវកាតព្វកិច្ចប្រគល់ផ្ទះនោះរួមទាំងឯកសារបញ្ជាក់នូវសិទ្ធិកាន់កាប់ផ្ទះនោះផងដែរ។

## ២. ភាតព្វកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ

ការប្រគល់វត្ថុ គឺជាការប្រគល់វត្ថុដែលលក់ទៅឲ្យអ្នកទិញ ស្របតាមកម្មវត្ថុនៃកិច្ចសន្យា។ ហើយវត្ថុនេះគឺជាអចលនវត្ថុ ដែលគូភាគីបានព្រមព្រៀងគ្នាហើយបានបំពេញចប់សព្វគ្រប់ក្នុងលក្ខខណ្ឌដែលអ្នកលក់បានប្រគល់វត្ថុដែលអ្នកទិញអាចប្រើប្រាស់ទៅតាមបំណងរបស់ខ្លួន។ យ៉ាងណាមិញមាត្រា៥៤៩ នៃក្រមរដ្ឋប្បវេណីបញ្ញត្តថា ***អ្នកលក់ត្រូវមានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុទៅឲ្យអ្នកទិញតាមកាលបរិច្ឆេទ នឹងតាមទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចសន្យា***។ ក្នុង ករណីយដែលភាគីសងខាងមិនបានកំណត់នៅក្នុងកិច្ច

[២២] មាត្រា៥៣០ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

សន្យានោះទេអ្នកលក់ត្រូវមានករណីយកិច្ចប្រគល់វត្ថុនោះនៅពេលដែលអ្នកទិញទាមទារ។ ប៉ុន្តែប្រសិនបើ បានចែងពីកាលបរិច្ឆេទប្រគល់ប្រាក់នោះសន្មត់ថាពេលកំណត់នៃការប្រគល់វត្ថុដែលជាកម្មវត្ថុក៏ដូចជាពេលកំណត់បង់ថ្លៃលក់ដែរ។ ក្នុងករណីមួយទៀត ដែលមិនបានកំណត់ពីទីកន្លែងប្រគល់ទេ នោះអ្នកលក់ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុ នៅនឹងកន្លែងដែលវត្ថុនោះស្ថិតនៅពេលធ្វើកិច្ចសន្យានឹងចំពោះមុខគូភាគី។ ចំពោះការលក់នៅនឹងកន្លែងជាទំលាប់នៅក្នុងកិច្ចសន្យាទំនួញអាចត្រូវគេចាត់ទុកថាប្រគល់វត្ថុ បើទោះបីជាមិនមានការប្រគល់វត្ថុទាំងមូលឲ្យអ្នកទិញក៏ដោយអាចធ្វើឡើងបាន ដោយការប្រគល់សោនៃអាគារ ឬប្រគល់ប័ណ្ណបញ្ជាក់សិទ្ធិផងដែរ។[២៣]

### កថាខណ្ឌទី២ កាតព្វកិច្ចផ្សេងៗទៀត

អ្នកលក់មិនត្រឹមតែមានកាតព្វកិច្ចចម្បងតែប៉ុណ្ណោះទេអាចមាននូវកាតព្វកិច្ចផ្សេងៗទៀតដែលអ្នកលក់ត្រូវបំពេញ ដូចជា កាតព្វកិច្ចត្រូវពន្យល់(១)រួមទាំងកាតព្វកិច្ចធានា(២)។

#### ១.កាតព្វកិច្ចត្រូវពន្យល់

អ្នកលក់ គឺត្រូវមានកាតព្វកិច្ចពន្យល់ប្រាប់ទៅកាន់អ្នកទិញ។ ការពន្យល់ គឺជាផ្នែកមួយយ៉ាងសំខាន់ណាស់ សម្រាប់ភាគីអ្នកទិញព្រោះថាប្រសិនបើអ្នកលក់មិនបានពន្យល់ឲ្យច្បាស់លាស់នោះទេ វាអាចធ្វើឲ្យអ្នកទិញមានការភាន់ច្រឡំទៅលើព្រំដែននិងសិទ្ធិផ្សេងជាដើម។ អ្នកលក់ត្រូវមានករណីយកិច្ចត្រូវពន្យល់ឲ្យបានច្បាស់លាស់ នូវខ្លឹមសារនៃករណីយកិច្ចដែលអ្នកលក់ទទួលបន្ទុក ទំនាក់ទំនងគតិយុត្តដែលទាក់ទងនិងវត្ថុ ឬសិទ្ធិដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ហើយជាពិសេសក្នុងករណីលក់អចលនវត្ថុត្រូវពន្យល់ដល់អ្នកទិញឲ្យបានច្បាស់លាស់ នូវខ្លឹមសារនៃសិទ្ធិការទទួលបន្ទុក និងព្រំដែននៃអចលន

[២៣]មាត្រា៥៥០ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

វត្ថុជាអាទិ៍។[២៧] ពីព្រោះដើម្បីកុំឲ្យកើតមានឡើងនៅបញ្ហានាពេលអនាគតគូភាគីគួរតែបង្កើតកិច្ចសន្យាលក់ទិញ ដោយយល់អំពីខ្លឹមសារចម្បងនៃកិច្ចសន្យានោះដោយត្រឹមត្រូវ។ ដូចនេះ អ្នកលក់ត្រូវមាននូវកាតព្វកិច្ច ធ្វើយ៉ាងណាពន្យល់ទៅអ្នកទិញឲ្យដឹងនិងយល់នូវព្រំដែន និងសិទ្ធិរបស់អ្នកលក់ ព្រមទាំងទំនាក់ទំនងគតិយុត្តផ្សេងទៀតដែលទាក់ទង និងសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ។ ជាទូទៅ អ្នកលក់មានព័ត៌មានអំពីវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ។ ដូចនេះ ករណីយកិច្ចដ៏ចាំបាច់របស់អ្នកលក់ត្រូវពន្យល់ទៅអ្នកទិញឲ្យបានក្បោះក្បាយនឹងច្បាស់លាស់។ ក្នុងករណី ដែលអ្នកលក់បំពានករណីយកិច្ចពន្យល់នេះអ្នកលក់នោះត្រូវទទួលខុសត្រូវចំពោះការខូចខាត ដែលបានកើតឡើងដោយសារការបំពាននោះ។ ប្រសិនបើ អ្នកលក់ពន្យល់ហេតុផលមិនពិតឬលាក់ហេតុពិត ដោយចេតនា ចំពោះចំនុចដែលមានឥទ្ធិពលលើការសម្រេចរបស់អ្នកទិញក្នុងការធ្វើ ឬមិនធ្វើកិច្ចសន្យាជាលទ្ធផលនាំឲ្យអ្នកទិញភាន់ច្រឡំ និងធ្វើកិច្ចសន្យាដោយផ្អែកលើការភាន់ច្រឡំនេះ អាចមានករណី ដែលកិច្ចសន្យានោះត្រូវបានលុបចោលដោយយកការឆបោក ឬការភាន់ច្រឡំមកធ្វើជាមូលហេតុ។[២៨] ដូចនេះកាតព្វកិច្ចពន្យល់របស់អ្នកលក់ គឺមានសារៈសំខាន់ណាស់ដើម្បីធ្វើការពន្យល់ទៅកាន់អ្នកទិញនៅព្រំដែន និងសិទ្ធិរបស់ខ្លួនព្រមទាំងព័ត៌មានផ្សេងៗទៀតដែលទាក់ទង់ទៅនឹងកម្មវត្ថុនោះ។

### ២. កាតព្វកិច្ចធានា

ជាទូទៅ អ្នកលក់មានកាតព្វកិច្ចត្រូវធានាថា ខ្លួនអាចមានលទ្ធិភាពក្នុងការផ្ទេរកម្មសិទ្ធិនឹងសិទ្ធិផ្សេៗទៀតទៅឲ្យអ្នកទិញ។ ការធានា ជាកាតព្វកិច្ចព្រោះថាការលក់វត្ថុមួយដោយគ្មានការធានានឹងនាំឲ្យ មានការបាត់បង់នូវផលប្រយោជន៍ពិសេសរបស់កិច្ចសន្យា

---

[២៧] មាត្រា៥២៩ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

[២៨] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី១ ករណីយកិច្ចរបស់អ្នកលក់។

លក់អចលនវត្ថុ។ ចំពោះការលក់ទិញអចលនវត្ថុនៅបុរី វិមានស អ្នកលក់ត្រូវមានកាតព្វកិច្ចធានាមានដូចជា:

- ធានាដល់រាល់ការសាងសង់នឹងត្រូវបញ្ចប់ជាស្ថាពរក្នុងអំឡុងពេល ១៨ខែ ដោយគិតចាប់ពីថ្ងៃផ្តិតស្នាមមេដៃលើកិច្ចព្រមពរៀង។ ប៉ុន្តែប្រសិនបើអ្នកលក់មិនបានបញ្ចប់ការសាងសង់រួចរាល់នៅក្នុងអំឡុងពេល ១៨ ខែនេះទេ នោះអ្នកលក់ត្រូវបង់ប្រាក់ឲ្យអ្នកទិញ ចំនួន ៥០$ ក្នុងមួយថ្ងៃ។
- ធានាដល់ការជួសជុលសំណង់រយៈពេល ៦ខែ ដោយគិតចាប់ពីថ្ងៃប្រគល់ផ្ទះជូនចំពោះអ្នកទិញ។
- ធានាក្នុងការតភ្ជាប់បណ្តាញទឹកភ្លើងចំនួន ១០A ជូនអ្នកទិញ។
- ផ្ទះល្វែង និងវីឡាក្រុមហ៊ុននឹងក្រាលការ៉ូខាងមុខផ្ទះពីទ្វារដល់ចំណីផ្លូវ។
- ផ្ទៃការ៉ូនៃផ្ទះខាងមុខរឺចំហៀងផ្ទះនិមួយៗ អ្នកលក់មានសិទ្ធិប្រើប្រាស់បានគ្រប់ពេលវេលាតាមតម្រូវការដូចជា ការរៀបចំបណ្តាញលូ,ទឹក,ភ្លើង,។ល។ ដោយគ្រាន់តែអ្នកលក់រៀបចំអោយបានល្អវិញក្រោយពីបានប្រើប្រាស់ទុកជាស្រេច។

**ផ្នែកទី២ ភាតព្វកិច្ចរបស់អ្នកទិញ**

បន្ទាប់ពីបង្កើតកិច្ចសន្យាលក់ទិញហើយនោះ អ្នកទិញមានកាតព្វកិច្ចចម្បងដែលត្រូវបំពេញចំពោះអ្នកលក់(កថាខណ្ឌទី១) និងមានការកំណត់ពីពេលវេលានៃការបង់ប្រាក់ថ្លៃទិញ (កថាខណ្ឌទី២) រួមទាំងទីកន្លែងដែលត្រូវបង់ប្រាក់(កថាខណ្ឌទី៣)។

**កថាខណ្ឌទី១ ភាតព្វកិច្ចចម្បងរបស់អ្នកទិញ**

ក្រោយពីបានធ្វើការសិក្សាទៅលើកាតព្វកិច្ចចម្បងរបស់អ្នកលក់ហើយ នោះអ្នកទិញក៏មានកាតព្វកិច្ចចម្បងដែលត្រូវបំពេញចំពោះអ្នកលក់វិញផងដែរ ដូចជា កាតព្វកិច្ចបង់ថ្លៃទិញ និងកាតព្វកិច្ចទទួលវត្ថុ។

**១. ភាតព្វកិច្ចបង់ថ្លៃទិញ**

អ្នកទិញមានកាតព្វកិច្ចបង់ថ្លៃទិញជាប្រាក់តាមការបរិច្ឆេទនិង ទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចសន្យា។[២៦] ក្នុងករណីយកិច្ចសន្យាលក់ទិញអចលនវត្ថុ ដែលមានកំណត់ពេលដើម្បីចុះបញ្ជីអចលនវត្ថុនោះត្រូវសន្មត់ថា ពេលកំណត់នៃការបង់ថ្លៃទិញក៏ដូចពេលកំណត់ប្រគល់អចលនវត្ថុដែរមិនត្រឹមតែប៉ុណ្ណោះ នៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុមិនបានកំណត់ពេលប្រគល់វត្ថុឬពេលដើម្បីចុះបញ្ជីអចលនវត្ថុទេ និងមិនបានកំណត់ពេលបង់ថ្លៃទិញ អ្នកទិញមានករណីយកិច្ចបង់ថ្លៃទិញ នៅពេលដែលអ្នកលក់ទាមទារឲ្យបង់ថ្លៃប្រាក់។

បើនៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុ មិនបានកំណត់ពីទីកន្លែងដែលត្រូវបានបង់ថ្លៃទិញហើយអចលនវត្ថុនៃការលក់ទិញត្រូវបានចុះបញ្ជីក្នុងការផ្ទេរកម្មសិទ្ធិ និងប្រគល់វត្ថុទៅឲ្យអ្នកទិញនោះការបង់ថ្លៃទិញត្រូវធ្វើឡើងព្រមគ្នា និងការប្រគល់វត្ថុផងដែរ។

អ្នកទិញមានករណីយកិច្ចបង់ប្រាក់ ដែលបានកំណត់នៅក្នុងកិច្ចសន្យាទៅតាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចសន្យា។ ចំពោះការបង់ប្រាក់លក់ទិញអចលនវត្ថុនៅបុរី វិមានស អ្នកទិញអាចមានជម្រើសពីរ ក្នុងការបង់ថ្លៃទិញអចលនវត្ថុ:

- **ជម្រើសទី ១ ការបង់ថ្លៃទិញទៅតាមដំណាក់កាល** គឺជាការបង់ថ្លៃទិញមួយដែលមានកំណត់នៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុ។ ជាគោលការណ៍ អ្នកទិញត្រូវប្រគល់ប្រាក់ថ្លៃទិញជូនទៅអ្នកលក់ទៅតាម ៥តំណាក់កាល ដែលមាននៅក្នុងកិច្ចសន្យាលក់ទិញរបស់បុរីបានកំណត់។ មានន័យថា ការបង់ប្រាក់ជា ៥ដំណាក់កាល នេះត្រូវធ្វើឡើងដោយដំណាក់កាលដំបូងអ្នកទិញត្រូវធ្វើការបង់ប្រាក់ដំបូងចំនួន ២០% ជាមុនសិនបន្ទាប់ពីបានធ្វើការបង់ប្រាក់កក់ជាលើកដំបូងហើយនោះ អ្នកទិញត្រូវធ្វើការបង់ជា ៤ ដំណាក់កាលទៀត ដោយលើកទី ២ អ្នកទិញត្រូវបង់ ២០%(មួយខែ

[២៦]មាត្រា៥៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ក្រោយ) លើកទី ៣ ២០%(មួយខែក្រោយ) លើទី ៤ ២០%(មួយខែក្រោយ) និងលើទី ៥ដែលផ្ទះសាងសង់រួចហើយអ្នកទិញត្រូវបង់ប្រាក់២០%ទៀត។ បន្ទាប់មកនៅពេលដែលអ្នកទិញបានធ្វើការបង់ប្រាក់គ្រប់ចំនួនទៅតាមកិច្ចសន្យារបស់បុរីហើយនោះ អ្នកលក់នឹងធ្វើការកាត់ប្លង់ផ្ទេរកម្មសិទ្ធិជូនទៅអ្នកទិញ។

- **ជម្រើសទី២ ការបង់ផ្តាច់** គឺជាការបង់ផ្តាច់មួយដែលអ្នកទិញបង់ទៅលើតម្លៃអចលនវត្ថុដែលបានកំណត់នៅក្នុងកិច្ចសន្យារបស់បុរី។ មិនត្រឹមតែប៉ុណ្ណោះប្រសិនបើអ្នកទិញមានការបង់ផ្តាច់ទៅលើអចលនវត្ថុនៅបុរីវិមាន ស នោះអ្នកទិញនឹងមានការបញ្ចុះតម្លៃ ៥% ទៅលើតម្លៃអចលនវត្ថុទាំងនោះ។

ឧទាហរណ៍: លោកស្រី សូនីកា បានទិញវីឡាមួយនៅបុរី វិមានស ដែលមានតម្លៃ ៣៨០,០០០ (សាមសិបប្រាំបីម៉ឺន)ដុល្លារអាមេរិក។ លោកស្រី បានទិញវីឡានេះដោយការបង់ប្រាក់ផ្តាច់ ដោយខាងបុរី បានបញ្ចុះតម្លៃ ៥% ដូច្នេះ លោកស្រី បង់ថ្លៃទិញត្រឹមតែ ៣៦១,០០០ (សាមសិបប្រាំមួយម៉ឺនមួយពាន់) ដុល្លារអាមេរិកតែប៉ុណ្ណោះ។

## ក. ការចរចារទាក់ទងទៅនឹងតម្លៃ

ក្នុងករណីវត្ថុដែលត្រូវបានប្រគល់មានវិការៈ ទោះបីជាថ្លៃលក់ត្រូវបានបង់រួចហើយក៏ដោយឬមិនទាន់បង់ក៏ដោយ ក៏អ្នកទិញអាចទាមទារបន្ថយថ្លៃលក់នោះ តាមសមាមាត្រនៃភាពខុសគ្នានៅពេលប្រគល់រវាងតម្លៃនៃវត្ថុដែលគ្មានវិការៈ និងតម្លៃនៃវត្ថុដែលត្រូវបានប្រគល់បានដែរ។ ប៉ុន្តែក្នុងករណីដែលអ្នកលក់ជួសជុលវិការៈនោះស្របតាមបញ្ញត្តមាត្រា ៥៤២ (សិទ្ធិទាមទារឲ្យអនុវត្តពេញលេញរបស់អ្នកទិញ) នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ឬករណីដែលអ្នកទិញមិនព្រមទទួលសេចក្តីស្នើផ្តល់ការជួសជុលរបស់អ្នកលក់ ដោយគ្មានមូលហេតុត្រឹមត្រូវនោះអ្នកទិញមិនអាចទាមទារឲ្យបន្ថយថ្លៃលក់បានឡើយ។[២៧]

---

[២៧] មាត្រា ៥៤៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

## ២. ភាតព្វកិច្ចទទួលវត្ថុ

នៅក្នុងករណីដែលអ្នកលក់បានបំពេញករណីយកិច្ចប្រគល់វត្ថុរួចរាល់ហើយនោះ អ្នកទិញត្រូវមានករណីយកិច្ចទទួលយកវត្ថុដែលខ្លួនបានទិញ។[២៩] ករណីយកិច្ចទទួលយកវត្ថុនេះ បានផ្ដល់ឲ្យអ្នកទិញនូវសិទ្ធិកាន់កាប់លើវត្ថុដែលបានព្រមពរៀងក្នុងកិច្ចសន្យាលក់ទិញ។ ករណីយកិច្ចទទួលវត្ថុនេះ កើតឡើងទន្ទឹមគ្នាជាមួយនឹងករណីយកិច្ចប្រគល់វត្ថុ។ ភាគីអ្នកទិញឬម្ចាស់ផ្ទះមិនអាចសាងសង់របង សំយាបនៅលើទីធ្លានៃការ៉ូនោះបានឡើយ។ ហើយចំពោះករណីមួយនេះនឹងត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកទិញបន្ត និងអ្នកទទួលសិទ្ធិបន្ត ពីភាគីអ្នកទិញជាបន្តបន្ទាប់រៀងរហូត។ មិនត្រឹមតែប៉ុណ្ណោះ នៅពេលដែលធ្វើការប្រកល់ ផ្ទះជូនទៅឲ្យអ្នកទិញរួចរាល់ហើយនោះ ទោះបីជាអ្នកទិញមិននៅ ឬក៏នៅក៏ដោយ អ្នកទិញ ត្រូវតែមានកាតព្វកិច្ចបង់ថ្លៃសេវាថែទាំសួនច្បារភ្លើងអំពូលបំភ្លឺផ្លូវព្រមទាំងសន្តិសុខ ទៅតាមប្រភេទផ្ទះ ដូចជា:

- ផ្ទះប្រភេទ វីឡាឃ្វីន ៥០$
- ផ្ទះប្រភេទ វីឡាភ្លោះ ៤០$ និង
- ផ្ទះប្រភេទ វីឡាកូនកាត់(ផ្ទះល្វែង) ២០$។

### កថាខណ្ឌទី២ ពេលវេលាបង់ប្រាក់

ពេលវេលានៃការបង់ប្រាក់ គឺតម្រូវឲ្យភាគីនៅក្នុងកិច្ចសន្យាត្រូវធ្វើការកំណត់ឲ្យបានច្បាស់លាស់ដើម្បីកុំអោយមានការយឺតយ៉ាវក្នុងការបង់ប្រាក់។ ពេលវេលាបង់ប្រាក់ក៏ជាចំនុចមួយដែលសំខាន់ផងដែរសម្រាប់គូភាគីនៃកិច្ចសន្យាត្រូវតែគោរពតាម។ មាត្រា ៥៥៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បញ្ញត្តផងដែរ ទាក់ទងនឹងករណីកិច្ចបង់ប្រាក់របស់អ្នកទិញ

[២៩] មាត្រា៥៥៤ នៃក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ដោយមាត្រានេះបានបញ្ញត្តថា *អ្នកទិញមានករណីយកិច្ចបង់ថ្លៃទិញជាប្រាក់ដែលបានកំណត់ក្នុងកិច្ចសន្យាតាមកាលបរិច្ឆេទ និង ទីកន្លែងដែលបានកំណត់ក្នុងកិច្ចសន្យា។* ទន្ទឹមនឹងនេះ ពេលវេលាបង់ប្រាក់នោះ ភាគីទាំងពីរអាចធ្វើការកំណត់ថាត្រូវធ្វើការបង់ប្រាក់នៅពេលណា គូភាគីអាចកំណត់ពេលវេលាបង់ប្រាក់តាមការព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យា។ ដូច្នេះ ការបង់ប្រាក់កើតមានឡើងនៅពេលដែលភាគីអ្នកលក់បានធ្វើការប្រគល់វត្ថុមកឲ្យអ្នកទិញ មានន័យថា ការកំណត់ពេលវេលានៃការប្រគល់វត្ថុសន្មត់ថា គឺជាពេលកំណត់នៃការបង់ប្រាក់ដូចគ្នានិងការប្រគល់វត្ថុដែរ។ យ៉ាងណាមិញ ការបង់ប្រាក់នៅបុរី វិមានស គឺអាចធ្វើទៅបានដោយមានការកំណត់ពេលវេលាច្បាស់ដែលមាននៅក្នុងកិច្ចសន្យា។ ឧទាហរណ៍: ក បានទិញអចលនវត្ថុនៅបុរី វិមានស នៅថ្ងៃទី ៤ខែ មិថុនា ឆ្នាំ២០១៨ ហើយភាគីអ្នកលក់បានកំណត់ថ្ងៃបង់ប្រាក់នៅក្នុងកិច្ចសន្យាឲ្យភាគីអ្នកទិញបង់ប្រាក់នៅថ្ងៃទី៤ ជារៀងរាល់ខែនិមួយៗ។ ដូច្នេះ ក ត្រូវតែបង់ប្រាក់ទៅតាមពេលវេលាដែលបានកំណត់នោះ។

### កថាខណ្ឌទី៣ ទីកន្លែងបង់ប្រាក់

ជាទូទៅចំពោះទីកន្លែងបង់ប្រាក់ ជាកន្លែងមួយសម្រាប់សម្គាល់ដើម្បីឲ្យអតិថិជនដែលត្រូវជាអ្នកទិញ មកធ្វើការបង់ប្រាក់ទៅតាមទីកន្លែងនៃកិច្ចសន្យា។ ចំពោះ ទីកន្លែងបង់ប្រាក់ដែលបុរី វិមានស បានធ្វើការកំណត់យកកន្លែងដែលសម្រាប់ឲ្យអតិថិជនឬអ្នកទិញអចលនវត្ថុនៅក្នុងបុរី វិមានស នេះតែម្តង។ ហើយវាជាការពិតបុរី វិមានស នេះមានទីតាំងស្ថិតនៅតាម បណ្តោយផ្លូវជាតិលេខ ១ ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

### កថាខណ្ឌទី៤ ការបំពានកាតព្វកិច្ចរបស់អ្នកទិញដែលមិនបានបង់ប្រាក់

ជាគោលការណ៍ នៅក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរី ការកំណត់តម្លៃអាស្រ័យទៅលើការផ្គត់ផ្គង់ និងតម្រូវការរបស់ខ្លួន។ ការកំណត់តម្លៃធ្វើឡើងដោយគូភាគីនៃកិច្ចសន្យា

ហើយទង្វើនេះធ្វើឲ្យស្របទៅនឹងផលប្រយោជន៍របស់ភាគីទាំងសងខាងរៀងៗខ្លួន។ ហើយតម្លៃដែល គូភាគីនៃកិច្ចសន្យាធ្វើការកំណត់នោះ ត្រូវតែស្របទៅនឹងឆន្ទៈពិតប្រាកដរបស់គូភាគីព្រោះថាភាគីទាំងពីរឈរលើមូលដ្ឋានសមភាពនៃកិច្ចសន្យា។ នៅពេលដែលភាគីទាំងពីរបានព្រមព្រៀងចំពោះតម្លៃនៅក្នុងកិច្ចសន្យាហើយ នោះអ្នកទិញត្រូវតែមានកាតព្វកិច្ចបង់ប្រាក់ទៅឲ្យអ្នកលក់វិញ ទៅតាមកិច្ចសន្យាដែលបានកំណត់។ ហើយក្នុងករណីដែលភាគីអ្នកទិញ មិនបានគោរពកាតព្វកិច្ចចំពោះការបង់ប្រាក់របស់ខ្លួនទៅឲ្យក្រុមហ៊ុន វិមានស ទៅតាមលក្ខខណ្ឌនៃកិច្ចសន្យានោះ អ្នកទិញនឹងត្រូវទទួលនូវការពិន័យដែលកើតចេញពីអំពើរបស់ខ្លួនដូចជា:

- ក្រុមហ៊ុនអភិវឌ្ឍលំនៅដ្ឋាន វិមានស បានធ្វើការដាក់ពិន័យទៅលើអ្នកទិញបើមិនបានបង់ប្រាក់តាមការកំណត់ដូចដែលមានចែងទៅតាមការកំណត់នៅក្នុងកិច្ចសន្យានោះទេ អ្នកទិញនឹងត្រូវបង់ប្រាក់ពិន័យ ១.៥% (មួយចុចប្រាំភាគរយ) ក្នុងមួយខែនៃចំនួនទឹកប្រាក់ដែលត្រូវបង់នោះ។
- ហើយប្រសិនបើអ្នកទិញខកខានមិនបានបង់ប្រាក់លើសពី ៦០ថ្ងៃ នោះទឹកប្រាក់ដែលអ្នកទិញបានបង់ទាំងអស់ និងត្រូវបានមកអ្នកលក់ហើយកិច្ចព្រមព្រៀងនេះ នឹងត្រូវចាត់ទុកជាមោឃៈដោយស្វ័យប្រវត្តិ ដោយអ្នកទិញគ្មានសិទ្ធិតវ៉ាអ្វីឡើយ។ ក្នុងករណីនេះ អ្នកលក់មានសិទ្ធិលក់ផ្ទះនេះឲ្យទៅអ្នកដទៃបានគ្រប់ពេលវេលា។
- ម៉្យាងវិញទៀត អ្នកទិញត្រូវតែយល់ព្រម ថាមិនធ្វើការកែប្រែ ឬ ផ្លាស់ប្តូរទម្រង់រចនាសម្ព័ន្ធផ្នែកខាងក្រៅនឹងផ្នែកខាងក្នុងបុរី លើកលែងតែមានការអនុញ្ញាតពីម្ចាស់បុរីទើបអាចធ្វើបាន[២៩]។

[២៩] យោងតាម ចំនុចទី ៤ នៃកិច្ចសន្យាលក់ទិញផ្ទះនៅបុរី វិមានស

ដូច្នេះ ភាគីអ្នកលក់និងអ្នកទិញត្រូវតែគោរពនូវលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យាដែលបានកំណត់ទៅតាមការព្រមព្រៀងរបស់គូភាគីនៃកិច្ចសន្យា។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវប្រធានបទស្តីពី កិច្ចសន្យាលក់ទិញអចលនវត្ថុនៅ បុរីវិមាន ស រួចមក កិច្ចសន្យាលក់ទិញ ជាកិច្ចសន្យាដែលតម្រូវឲ្យមានការផ្ទេរកម្មសិទ្ធិដោយមានការចុះបញ្ជីឲ្យបានត្រឹមត្រូវ ។ ការបង្កើតកិច្ចសន្យា ផ្តល់ជាអានុភាពបង្កើតសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី។ ជាការពិតណាស់ ការសម្តែងឆន្ទៈនៃការព្រមព្រៀង រវាងគូភាគីនៃកិច្ចសន្យា មានគោលបំណង ដើម្បីទទួលបាន អត្ថប្រយោជន៍ ដែលកើតចេញពីការសម្តែងឆន្ទៈនោះ។ អាស្រ័យហេតុនេះ សេរីភាពក្នុងការបង្ហាញឆន្ទៈ ជាសេរីភាពរបស់បុគ្គលមានសិទ្ធិចុះកិច្ចសន្យា និងកំណត់ពីកម្មវត្ថុនៃកិច្ចសន្យាផងដែរ។

នៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុនេះ ក៏បានកំណត់ផងដែរ អំពីករណីយកិច្ចរបស់ គូភាគី មានដូចជា: ករណីយកិច្ចផ្ទេរកម្មសិទ្ធិ ករណីយកិច្ចប្រគល់វត្ថុ ករណីយកិច្ចរក្សាទុកវត្ថុ ករណីយកិច្ចធានា ករណីយកិច្ចបង់ថ្លៃ និងករណីយកិច្ចទទួលវត្ថុជាអាទិ៍។ ដើម្បីក្លាយខ្លួនជាកម្មសិទ្ធិករ ការផ្ទេរកម្មសិទ្ធិត្រូវចុះបញ្ជី។ សមត្ថកិច្ចនៃការចុះបញ្ជីទទួលបន្ទុកដោយស្ថាប័នសុរិយោដី។

បើយើងសង្កេត ទៅលើសកម្មភាពចំណងគតិយុត្តទាក់ទងរវាងទ្រព្យ និងបុគ្គលវាពិតជាមានបញ្ហាមួយចំនួនតែងតែកើតមានឡើងផងដែរ ដូចជាភាគីនៃកិច្ចសន្យាមិនគោរពកាតព្វកិច្ចតាមការសម្តែងឆន្ទៈរបស់ខ្លួន វាអាចកើតមានក្នុងករណី អ្នកលក់មិនបានបញ្ចប់ការសាងសង់ឲ្យរួចរាល់នៅក្នុងអំឡុងពេល១៨ខែ ជូនអ្នកទិញតាមកាលកំណត់ ឬ តែប្រែមិនព្រមលក់អចលនវត្ថុដែលជាកម្មវត្ថុនោះឲ្យទៅអ្នទិញ។ ដូច្នេះហើយដើម្បីជាជំនួយក្នុងការដោះស្រាយបញ្ហាដែលកើតមានខាងលើនេះ អ្នកលក់គប្បីដោះស្រាយជម្លោះដោយការសម្រុះសម្រួលគ្នាតាមសន្តិវិធី ។ ប្រសិនបើ ពុំទទួលបានជោគជ័យនោះទេ ភាគីទាំងពីរ

អាចដាក់ជម្លោះដែលកើតចេញពីកិច្ចសន្យាលក់ទិញនេះ ជូនតុលាការដែលមានសមត្ថកិច្ចបាន។

ទន្ទឹមនឹងនេះ យើងខ្ញុំសង្ឃឹមថា ចំណាងគតិយុត្តដែលប្រព្រឹត្តទៅ ដោយមានការគោរពច្បាប់ និងអនុវត្តតាមឆន្ទៈរបស់ភាគីបានត្រឹមត្រូវ វាពិតជាឈានទៅរកទំនាក់ទំនងដ៏មានប្រសិទ្ធិភាព ដើម្បីទទួលបាននូវលទ្ធផលតាមក្តីបំណង និងដំណោះស្រាយដោយយុត្តិធម៌។ ជាពិសេស គូភាគី គួតែស្វែងយល់ឲ្យបានច្បាស់ពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន នៅក្រោយពេលដែលបានបង្កើតចំណាងកាតព្វកិច្ច។ នៅពេលប្រជាពលរដ្ឋ យល់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ព្រមទាំងមានការគោរពច្បាប់ នោះទំនាស់ត្រូវបានកាត់បន្ថយ និងឈានទៅរកការលុបបំបាត់នូវទំនាស់ផងដែរ។

# ឯកសារយោង

# ឯកសារយោង

**បទដ្ឋានគតិយុត្ត:**

- រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣
- ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ភូមិបាល លេខ នស/រតក/១៨ ,ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

**សៀវភៅ:**

- លោកសាស្ត្រាចារ្យ ខាំ សុមករា សៀវភៅនីតិរដ្ឋប្បវេណី បោះពុម្ពលើកទី២ ឆ្នាំ ២០១២
- លោកសាស្ត្រាចារ្យ គង់ សុភ័ក្រ មេរៀន នីតិកាតព្វកិច្ច ឆ្នាំ ២០១៦
- លោកមេធាវី អ៊ីវ ប៉ូលី សៀវភៅ(មេរៀនសង្ខេប) នីតិរដ្ឋប្បវេណី ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។
- សាស្ត្រាចារ្យ ណូមឹរ៉ា តូយ៉ូហ៊ីរ៉ូ សេចក្តីផ្តើម នីតិរដ្ឋប្បវេណី ខែមេសា ឆ្នាំ២០១៤។
- គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* ភាគ២ គន្លឹទី៤ ឆ្នាំ២០១០។
- គណៈកម្មការទទួលបន្ទុកកិច្ចការផ្នែកច្បាប់រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីកម្ពុជា និងក្រុមការងារជប៉ុនដែលទទួលបន្ទុករៀបចំ សេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១។*
- ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ* ២ ខែមេសា ឆ្នាំ ២០១៣។

**សន្ធានុក្រម:**

- សទ្ធានុក្រម នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧។

# ឧបសម្ព័ន្ធ

១/.សម្រេចមាត្រា៣,១៦,១៧,២២,២៤,២៦,៣០,១២០,៣៣៧,៣៣៨,៣៤០,៣៦៤, ៣៦៥,៣៦៦,៣៦៨,៥១៥ ដល់មាត្រា៥៥៩ នៃក្រមរដ្ឋប្បវេណីលេខ នស/រកម/១២០៧/ ០៣០, ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

២/. សម្រេចមាត្រា២នៃច្បាប់ភូមិបាល លេខ នស/រតក/១៨ ,៣០ សីហា ឆ្នាំ២០០១។

៣/. កិច្ចសន្យាលក់ទិញអចលនវត្ថុនៅបុរី វិមានស។

# គន្ថីទី ១

# បទប្បញ្ញត្តិទូទៅ

## ជំពូកទោល

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–** ច្បាប់ទូទៅនៃនីតិឯកជន

ក្រមនេះ បញ្ញត្តអំពីគោលការណ៍ទូទៅដែលទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះ ត្រូវយកមកអនុវត្ត ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និង ទំនាក់ទំនងញាតិ លើកលែងតែមានកំណត់ផ្សេង នៅក្នុងច្បាប់ពិសេស ។

**មាត្រា ២.–** គោលការណ៍ជាមូលដ្ឋាន

ក្រមនេះ កំណត់អំពីគោលការណ៍នៃការធានាសេចក្ដីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និង សិទ្ធិលើទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។

**មាត្រា ៣.–** គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន

ក្រមនេះ គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និង បញ្ញត្តអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល ។ នីតិបុគ្គលសាធារណៈ ដែលនៅក្នុងទំនាក់ទំនងនៃការជួញដូរ ត្រូវចាត់ទុកថាជាបុគ្គលឯកជន ។

**មាត្រា ៤.–** ការហាមឃាត់មិនឱ្យប្រើប្រាស់សិទ្ធិដោយបំពាន

ទោះបីជាសិទ្ធិក៏ដោយ ក៏ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយបំពានឡើយ ។ នៅក្នុងករណីដែលបានប្រើប្រាស់សិទ្ធិ ដោយបំពានហួសពីទំហំនៃការការពារ ដែលត្រូវបានបញ្ញត្តទុក មិនអាចទទួលស្គាល់អានុភាពនៃការប្រើសិទ្ធិនោះឡើយ ។

**មាត្រា ៥.–** គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់

ការប្រើសិទ្ធិ និង ការអនុវត្តករណីយកិច្ច ត្រូវធ្វើឡើងដោយសុចរិត ផ្អែកតាមភាពស្មោះត្រង់ ។

ខាត ដោយអ្នកដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល នោះ ដោយយោងទៅតាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូលបានឡើយ ។

## ផ្នែកទី ៣

## សមត្ថភាពខាងឆន្ទៈ

**មាត្រា ១៤.–** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

**មាត្រា ១៥.–** និយមន័យនៃសកម្មភាព

ពាក្យ "សកម្មភាព" ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

## ផ្នែកទី ៤

## សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.–** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

### កថាភាគទី ១

### អនីតិជន

**មាត្រា ១៧.–** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ១៨.–** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ១៩.–** ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន ។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ ។

**មាត្រា ២០.–** អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

**មាត្រា ២១.–** ល័ក្ខខ័ណ្ឌនៃអត្តាធីនភាព

១-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបាន

តាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អគ្គាធិនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា ។

២-អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអគ្គាធិនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអគ្គាធិនភាព មិនត្រូវរលត់ឡើយ ។

**មាត្រា ២២.–** អានុភាពនៃអគ្គាធិនភាព

អនីតិជនដែលទទួលអគ្គាធិនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

**មាត្រា ២៣.–** កិច្ចសន្យាការងាររបស់អនីតិជន

១-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) និង មាត្រា ១០៨០ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះក៏ដោយ ក៏អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានដែរ ។

២-កិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនមានអានុភាពចំពោះសាមីអនីតិជនឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលសាមីអនីតិជនផ្តល់សច្ចានុមតិលើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជនអាចធ្វើឱ្យខូចផលប្រយោជន៍ដល់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋបាល អាចរំលាយកិច្ចសន្យានោះ ឆ្ពោះទៅអនាគតបាន ។

## កថាភាគទី ២

## ជននៅក្រោមអាណាព្យាបាលទូទៅ

**មាត្រា ២៤.–** ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ

១-ចំពោះជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំនៅពេលដែលមានពាក្យសុំ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមហិតូបត្ថម្ភ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភចំពោះជននោះ ។

**មាត្រា ២៥.–** អត្ថន័យនៃជននៅក្រោមអាណាព្យាបាលទូទៅ និង ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

ជនដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ត្រូវហៅថា ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ២៦.–** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ២៧.–** ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៣

## ជននៅក្រោមហិតូបត្ថម្ភ

**មាត្រា ២៨.–** ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ

១-ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅចំពោះជននោះ ។

**មាត្រា ២៩.–** អត្ថន័យនៃជននៅក្រោមហិតូបត្ថម្ភ និង ការជ្រើសតាំងហិតូបត្ថម្ភកៈ

ជនដែលបានទទួលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។

**មាត្រា ៣០.–** សិទ្ធិលុបចោលសកម្មភាព

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែល

# គន្ថីទី ៣
# សិទ្ធិប្រត្យក្ស

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១
### វត្ថុ

**មាត្រា ១១៩.–** និយមន័យនៃវត្ថុ

ក្នុងក្រមនេះ វត្ថុសំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង ។

**មាត្រា ១២០.–** ចលនវត្ថុ និង អចលនវត្ថុ

១-វត្ថុត្រូវបានចែកជាចលនវត្ថុ និង អចលនវត្ថុ ។

២-អចលនវត្ថុសំដៅទៅលើ ដីធ្លី និង វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ ។

៣-ចលនវត្ថុសំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ ។

៤-បញ្ញត្តិស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន លើកលែងតែមានបញ្ញត្តិក្នុងច្បាប់ពិសេស ។

**មាត្រា ១២១.–** សមាសភាគនៃវត្ថុ

ចំពោះសមាសភាគនៃវត្ថុអ្វីមួយ ដែលមិនអាចបែងចែកបានដោយមិនបំបែកវត្ថុនោះ ឬ ដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃសមាសភាគនោះទេ ភាគនៃវត្ថុនោះមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯកភាជ្យបានឡើយ ។

ឃ៤) ហ៊ីប៉ូតែក

ឃ៥) សិទ្ធិប្រាតិភោគដោយអនុប្បទាន ។

## ផ្នែកទី ៣
## គោលការណ៍នៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស

**មាត្រា ១៣៣.-** ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង

ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ត្រូវមានអានុភាព តាមការព្រមព្រៀងរវាងភាគី ។

**មាត្រា ១៣៤.-** ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស

១-ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ ក្រៅពីសិទ្ធិកាន់កាប់ សិទ្ធិឃាត់ទុក សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ មិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំបានចុះបញ្ជីសិទ្ធិនោះ តាមបញ្ញត្តិនៃច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ដែលទាក់ទងនឹងការចុះបញ្ជី ។

២-អនុប្បទាននូវសិទ្ធិប្រត្យក្សលើចលនវត្ថុទៅបុគ្គលណាមួយ មិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំបានផ្ទេរការកាន់កាប់ចលនវត្ថុទៅបុគ្គលនោះទេ ។

**មាត្រា ១៣៥.-** ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង

ទោះបីមានបញ្ញត្តិនៃមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង) និង មាត្រា ១៣៤ (ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) នៃក្រមនេះ ក៏ដោយ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង មិនមានអានុភាព បើមិនបានចុះបញ្ជី ដោយយោងតាមបញ្ញត្តិនៃច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត ស្តីពីការចុះបញ្ជី ។

**មាត្រា ១៣៦.-** ព្យាកុលភាព

១-ចំពោះវត្ថុតែមួយ បើកម្មសិទ្ធិលើវត្ថុនោះ និង សិទ្ធិប្រត្យក្សផ្សេងទៀតលើវត្ថុនោះ ធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិប្រត្យក្សផ្សេងនោះ ត្រូវរលត់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលវត្ថុនោះ ឬ សិទ្ធិប្រត្យក្សនោះ ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន ។

២-បើសិទ្ធិប្រត្យក្សក្រៅពីកម្មសិទ្ធិ និង សិទ្ធិផ្សេងទៀតដែលមានកម្មវត្ថុជាសិទ្ធិប្រត្យក្សនោះ ធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិនោះត្រូវរលត់ ។ ក្នុងករណីនេះ បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវអនុវត្តចំពោះសិទ្ធិកាន់កាប់ឡើយ ។

**មាត្រា ១៣៧.-** អានុភាពក្នុងការសន្មតនៃការចុះបញ្ជី

១-នៅពេលដែលបានចុះសិទ្ធិក្នុងបញ្ជីអចលនវត្ថុហើយ សិទ្ធិនេះត្រូវបានសន្មតថាជាសិទ្ធិរបស់អ្នកដែលមានឈ្មោះ នៅក្នុងបញ្ជីនោះ ។

២-បើសិទ្ធិដែលបានចុះបញ្ជីអចលនវត្ថុហើយ ត្រូវបានលុបចេញពីបញ្ជីអចលនវត្ថុនោះ សិទ្ធិនោះត្រូវបានសន្មតថា បានរលត់ ។

## ជំពូកទី ២

## កម្មសិទ្ធិ

### ផ្នែកទី ១

### ខ្លឹមសារ និង កម្រិតនៃកម្មសិទ្ធិ

**មាត្រា ១៣៨.-** និយមន័យនៃកម្មសិទ្ធិ

កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយសេរីបាន នៅក្នុងទំហំដែលច្បាប់បានកម្រិត ។

ដោយច្បាប់ ។

**មាត្រា ៣១០.-** និយមន័យនៃការបង្ហាញឆន្ទៈ

១-ការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត ហៅថា ការបង្ហាញឆន្ទៈ ។

២-ការបង្ហាញឆន្ទៈ ត្រូវមានអានុភាព ចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះ បានទៅដល់ភាគីម្ខាងទៀត ។

**មាត្រា ៣១១.-** និយមន័យនៃកិច្ចសន្យា

កិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ។

**មាត្រា ៣១២.-** និយមន័យនៃសកម្មភាពឯកតោភាគី

១-សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬតាមបញ្ញត្តិនៃច្បាប់ ។

២-បញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) និង ផ្នែកទី ៤ (ការតំណាង) នៃជំពូកទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពឯកតោភាគី ។

## ផ្នែកទី ២
## ប្រភេទ និង បែបយ៉ាងនៃកាតព្វកិច្ច

**មាត្រា ៣១៣.-** ប្រភេទនៃកាតព្វកិច្ច

ក្រៅពីគោលបំណងផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លើវត្ថុ ឬ ប្រាក់ កាតព្វកិច្ចអាចមានគោលបំណងធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ ។

# ជំពូកទី ២
# ការបង្ហាញឆន្ទៈ និង កិច្ចសន្យា

## ផ្នែកទី ១
## ការបង្កើតកិច្ចសន្យា

**មាត្រា ៣៣៦.-** ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្វីការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

**មាត្រា ៣៣៧.-** និយមន័យនៃសំណើ និង ស្វីការ

១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។

២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

៣-ស្វីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។

៤-ស្វីការត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្វីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្វីការដល់ ឬ មុនពេលស្វីការដល់ នោះអានុភាពនៃស្វីការ មិនត្រូវកើតឡើយ ។

**មាត្រា ៣៣៨.-** សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ

១-សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្វីការ ។ អំឡុងពេល

សម្រាប់ស្វីការ ត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង ។

២-សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសម្រាប់ស្វីការ មិនអាចដកវិញបានទេ ។

៣-ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្វីការ ក្នុងអំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិនៅពេលផុតអំឡុងពេលសម្រាប់ស្វីការ ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្វីការនោះ សំណើនោះក៏ត្រូវបាត់បង់អានុភាពដែរ ។

**មាត្រា ៣៣៩.-** សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ

១-ចំពោះសំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការរវាងគូភាគីដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព ។

២-ចំពោះសំណើដែលធ្វើរវាងគូភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ ។

៣-ការដកសំណើត្រូវមានអានុភាព លុះត្រាតែការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្វីការ ។

**មាត្រា ៣៤០.-** ពេលនៃការបង្កើតកិច្ចសន្យា : គោលការណ៍នៃការមកដល់នៃស្វីការ

កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលដំណឹងអំពីស្វីការបានមកដល់អ្នកស្នើ ។

**មាត្រា ៣៤១.-** ការមកដល់យឺតយ៉ាវនៃស្វីការ

១-ក្នុងករណីដែលការជូនដំណឹងអំពីស្វីការ ចំពោះសំណើដែលមានអំឡុងពេល

ទាមទារឱ្យភាគីម្ខាងទៀតអនុវត្ត ។

គ-អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬ មួយផ្នែក ចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើមានថបនីយថា ខ្លួនមិនបានផ្តល់សច្ចានុមតិ នៅពេលដែលហេតុដែលបានកំណត់នៅក្នុងករណីទាំងបីខាងលើនោះ កើតឡើង ។

**មាត្រា ៣៦៣.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល

១-ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេល ៣ (បី) ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល និង សិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារការលុបចោលនោះ ត្រូវរលត់ ។ បញ្ញត្តិស្តីពីការផ្អាកអាជ្ញាយុកាលមិនត្រូវយកមកអនុវត្តឡើយ ចំពោះអំឡុងពេលនេះ ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើហួសអំឡុងពេល ១០ (ដប់) ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព នោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ ។

៣-ក្នុងករណីដែលបុគ្គលច្រើននាក់មានសិទ្ធិលុបចោលនូវសកម្មភាពតែមួយ បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះត្រូវយកមកអនុវត្ត ចំពោះសិទ្ធិលុបចោលនៃបុគ្គលនីមួយៗនោះ ។

## ផ្នែកទី ៤
## ការតំណាង

**មាត្រា ៣៦៤.–** និយមន័យនៃការតំណាង

ការតំណាងសំដៅទៅលើទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យាត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាង ធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀត

ដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះ គឺ ធ្វើសម្រាប់ម្ចាស់សិទ្ធិ ក្នុងទំហំនៃសិទ្ធិតំណាង ។

**មាត្រា ៣៦៥.-** កំណើតនៃសិទ្ធិតំណាង

សិទ្ធិតំណាងកើតមានឡើងដោយកិច្ចសន្យារវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ឬ ដោយបញ្ញត្តិនៃច្បាប់ ។

**មាត្រា ៣៦៦.-** ទំហំនៃសិទ្ធិតំណាង

១-ទំហំនៃសិទ្ធិតំណាងត្រូវកំណត់ដោយកិច្ចសន្យាដែលប្រគល់សិទ្ធិតំណាងទៅឱ្យអ្នកតំណាង ។ ក្នុងករណីដែលសិទ្ធិតំណាងត្រូវកើតឡើងដោយបញ្ញត្តិនៃច្បាប់ ទំហំនៃសិទ្ធិតំណាងក៏ត្រូវកំណត់ដោយច្បាប់នោះដែរ ។

២-ក្នុងករណីដែលទំហំនៃសិទ្ធិតំណាងមិនបានកំណត់ទេ អ្នកតំណាងត្រូវមានសិទ្ធិចំពោះអំពើថែរក្សា និង អំពើកែលំអ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះអំពើកែលំអដែលផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃការតំណាង ។

**មាត្រា ៣៦៧.-** ការកម្រិតសិទ្ធិតំណាង

១-ទោះបីក្នុងទំហំនៃសិទ្ធិតំណាងក៏ដោយ ចំពោះអំពើដែលផលប្រយោជន៍របស់អ្នកតំណាង និង របស់ម្ចាស់សិទ្ធិ មានភាពផ្ទុយគ្នា អ្នកតំណាងគ្មានសិទ្ធិទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការយល់ព្រម ពីម្ចាស់សិទ្ធិ ។

២-ចំពោះកិច្ចការជំនួញរវាងម្ចាស់សិទ្ធិ និង អ្នកតំណាង ត្រូវសន្មតថា ផលប្រយោជន៍ម្ចាស់សិទ្ធិ និង ផលប្រយោជន៍អ្នកតំណាង មានភាពផ្ទុយគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកតំណាង ធ្វើជាតំណាងឱ្យម្ចាស់សិទ្ធិផង ធ្វើជាតំណាងឱ្យតតិយជនផង ហើយផលប្រយោជន៍ម្ចាស់សិទ្ធិ និង ផលប្រយោជន៍តតិយជន មានភាពផ្ទុយគ្នា ។

**មាត្រា ៣៦៨.-** មូលហេតុនៃការរលត់សិទ្ធិតំណាង

១-សិទ្ធិតំណាងដែលបានទទួលពីម្ចាស់សិទ្ធិដោយកិច្ចសន្យា ត្រូវរលត់ដោយសារមូលហេតុខាងក្រោមនេះ :

# គន្ថីទី ៥
# កិច្ចសន្យាសំខាន់ៗ និង អំពើអនីត្យានុកូល

## ជំពូកទី ១
## ការលក់ទិញ

### ផ្នែកទី ១
### លក្ខណៈនៃការលក់ និង ការបង្កើតកិច្ចសន្យាលក់ទិញ

**មាត្រា ៥១៥.-** និយមន័យនៃការលក់ទិញ

ការលក់ទិញសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិ ឱ្យទៅភាគីម្ខាងទៀតហៅថា អ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឱ្យអ្នកលក់ ។

**មាត្រា ៥១៦.-** ការបង្កើតកិច្ចសន្យាលក់ទិញ

កិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើតឡើង ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ ។ ប៉ុន្តែ ភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬ លិខិតឯកជន ជាល័ក្ខខ័ណ្ឌសម្រាប់ការបង្កើតកិច្ចសន្យាបាន ។

**មាត្រា ៥១៧.-** ការសន្យាលក់ទិញជាមុនដោយឯកតោភាគី

១-ក្នុងករណីដែលភាគីតែម្ខាងសន្យាជាមុនក្នុងការលក់ ឬ ទិញ ការលក់ទិញនេះនឹងមានអានុភាពចាប់តាំងពីពេលដែលភាគីម្ខាងទៀតបង្ហាញឆន្ទៈបំពេញការទិញ ឬ លក់ចំពោះអ្នកសន្យានោះ ។

២-ប្រសិនបើអំឡុងពេលសម្រាប់ការបង្ហាញឆន្ទៈដែលបានចែងក្នុងកថាខណ្ឌទី ១ នេះមិនត្រូវបានកំណត់ទេ អ្នកសន្យាជាមុនអាចកំណត់នូវអំឡុងពេលសមរម្យមួយ ហើយ

អាចដាស់តឿនឱ្យភាគីម្ខាងទៀតបង្ហាញឆន្ទៈថា ព្រម ឬ មិនព្រមបំពេញការទិញ ឬ លក់នៅក្នុងអំឡុងពេលនោះ ។ ក្នុងករណីដែលភាគីម្ខាងទៀតមិនបានបង្ហាញឆន្ទៈនៅក្នុងអំឡុងពេលកំណត់ទេ ការសន្យាជាមុននោះ ត្រូវបាត់បង់អានុភាព ។

**មាត្រា ៥១៨.-** ប្រាក់កក់

បើអ្នកទិញបានបង់ប្រាក់កក់ទៅឱ្យអ្នកលក់ អ្នកទិញអាចរំលាយកិច្ចសន្យាលក់ទិញដោយបោះបង់ចោលប្រាក់កក់នោះបាន រីឯអ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញដោយសងប្រាក់ស្មើនឹងពីរដងនៃប្រាក់កក់នេះមកវិញបានដែរ ។ ប៉ុន្តែ ភាគីមិនអាចរំលាយកិច្ចសន្យាបានឡើយ ក្រោយពេលភាគីម្ខាងទៀតបានចាប់ផ្តើមអនុវត្តកិច្ចសន្យាហើយ ។

**មាត្រា ៥១៩.-** ការលក់ដោយមានការភ្លក់សាក

១-ការលក់របស់ណាដែលមានទំនៀមទំលាប់តម្រូវឱ្យមានការភ្លក់សាកមុននឹងទិញ ត្រូវមានអានុភាពនៅពេលអ្នកទិញបានយល់ព្រម ក្រោយពេលបានភ្លក់សាករួចហើយ ។

២-ក្នុងករណីដែលមិនបានកំណត់អំឡុងពេលសម្រាប់អ្នកទិញដើម្បីយល់ព្រម អ្នកលក់អាចដាស់តឿនឱ្យអ្នកទិញឆ្លើយច្បាស់អំពីការយល់ព្រម ឬ មិនយល់ព្រម ដោយកំណត់អំឡុងពេលសមរម្យបាន ។ ក្នុងករណីដែលអ្នកទិញមិនបានឆ្លើយច្បាស់ ក្នុងអំឡុងពេលនោះ ត្រូវចាត់ទុកថា អ្នកទិញបដិសេធក្នុងការធ្វើកិច្ចសន្យា ។

**មាត្រា ៥២០.-** ការលក់ដោយមានការប្រើសាក

១-ចំពោះការលក់ទិញដោយមានការប្រើសាក កិច្ចសន្យាលក់ទិញនោះមានអានុភាពនៅពេលដែលអ្នកទិញបានយល់ព្រមក្នុងអំឡុងពេលប្រើសាក ឬ អំឡុងពេលប្រើសាកនោះកន្លងហួស ដោយអ្នកទិញមិនបានបង្ហាញឆន្ទៈទេ ។ ក្នុងករណីដែលអ្នកទិញបដិសេធមិនទទួលវត្ថុដែលជាកម្មវត្ថុ កិច្ចសន្យាលក់ទិញនោះ ត្រូវចាត់ទុកថា មិនត្រូវបានបង្កើតឡើយ ។

២-ក្នុងករណីដែលមិនបានកំណត់អំឡុងពេលប្រើសាកនៅក្នុងកិច្ចសន្យា អ្នកលក់អាចដាស់តឿនឱ្យអ្នកទិញឆ្លើយច្បាស់អំពីការយល់ព្រម ឬ មិនយល់ព្រម ដោយកំណត់

អំឡុងពេលសមរម្យបាន ។ ក្នុងករណីដែលអ្នកទិញមិនបានឆ្លើយច្បាស់ ក្នុងអំឡុងពេលនោះ ហើយបន្តប្រើសាកវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានោះ ត្រូវចាត់ទុកថា អ្នកទិញបានយល់ព្រម ។

**មាត្រា ៥២១.-** ថ្លៃលក់ទិញ

១-ភាគីនៃកិច្ចសន្យាត្រូវកំណត់ចំនួនប្រាក់នៃថ្លៃលក់ទិញ ឬ វិធីកំណត់ចំនួនប្រាក់នោះ នៅក្នុងកិច្ចសន្យា ។

២-ចំនួនប្រាក់នៃថ្លៃលក់ទិញអាចត្រូវបានកំណត់ ដោយយោលទៅតាមតម្លៃនៃទំនិញណាមួយនៅទីផ្សារក្នុងពេលបច្ចុប្បន្ន ឬ អនាគត ឬ ដោយផ្អែកលើការវាយតម្លៃដែលធ្វើដោយតតិយជនដែលត្រូវបានជ្រើសរើស តាមរបៀបកំណត់ដោយគូភាគី ។ ក្នុងករណីដែលការវាយតម្លៃរបស់តតិយជនត្រូវបានធ្វើឡើងដោយភាន់ច្រឡំ ឬ ករណីដែលការវាយតម្លៃនោះ ច្បាស់ជាផ្ទុយនឹងសមភាព ភាគីនៃកិច្ចសន្យាដែលទទួលការខូចខាតផលប្រយោជន៍របស់ខ្លួន ដោយសារការវាយតម្លៃនោះ អាចតវ៉ាចំពោះការវាយតម្លៃនោះបាន ។

៣-ភាគីនៃកិច្ចសន្យាអាចកំណត់ចំនួនថ្លៃលក់ទិញដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ ឬ ដោយឱ្យអ្នកទិញបង់ធនលាភ ដែលមិនកំណត់ពេល ឬ ធនលាភមួយជីវិតបាន ។ ប៉ុន្តែ ក្នុងករណីដែលតតិយជនវាយតម្លៃ ដោយយោលទៅតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ថ្លៃលក់ទិញត្រូវបានកំណត់ដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ លើកលែងតែករណីដែលគូភាគីប្រគល់សិទ្ធិទៅតតិយជនដោយជាក់លាក់ ។

**មាត្រា ៥២២.-** សោហ៊ុយក្នុងការលក់ទិញ

ចំពោះសោហ៊ុយធ្វើលិខិត ឬ សោហ៊ុយផ្សេងៗដែលត្រូវចំណាយក្នុងការធ្វើកិច្ចសន្យាលក់ទិញ ភាគីទាំងសងខាងត្រូវចេញស្មើគ្នា លើកលែងតែករណីដែលមានការកំណត់ផ្សេងដោយគូភាគី ។

**មាត្រា ៥២៣.-** ការអនុវត្តដូចគ្នាចំពោះកិច្ចសន្យាទូទៅដែលយកតម្លៃថ្នូរ

បញ្ញត្តិនៃជំពូកទី ១ (ការលក់ទិញ) នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកិច្ចសន្យាដែលយកតម្លៃថ្នូរ ក្រៅពីកិច្ចសន្យាលក់ទិញ ។

## ផ្នែកទី ២
## ភាគីនៃកិច្ចសន្យាលក់ទិញ និង កម្មវត្ថុនៃកិច្ចសន្យាលក់ទិញ

**មាត្រា ៥២៤.-** ភាគីនៃកិច្ចសន្យាលក់ទិញ

រូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយអាចលក់ ឬ ទិញបាន លើកលែងតែក្នុងករណីដែលច្បាប់ហាមឃាត់ ។

**មាត្រា ៥២៥.-** បុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន (មួយ)

១-អ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់ តាមផ្លូវតុលាការ ឬ តាមកិច្ចសន្យា មិនអាចក្លាយជាអ្នកទិញ ឬ ជាអ្នកទិញដោយការលក់ដោយបង្ខំ នូវទ្រព្យសម្បត្តិដែលខ្លួនបានទទួលភារកិច្ចលក់ ដោយផ្ទាល់ខ្លួន ឬ តាមរយៈអន្តរការី បានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមន្ត្រីរាជការដែលទទួលបន្ទុកចាត់ការ ការលក់ដោយបង្ខំ ឬ ទទួលបន្ទុកគ្រប់គ្រងការលក់ដោយបង្ខំ ។

៣-ចំពោះការលក់ទិញដែលផ្ទុយនឹងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ មានតែកម្មសិទ្ធិករនៃវត្ថុមុនពេលលក់ ឬ សន្តតិជនឬប្រតិសិទ្ធិរបស់កម្មសិទ្ធិករនោះទេ ទើបអាចលុបចោលកិច្ចសន្យានេះបាន ។

**មាត្រា ៥២៦.-** បុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន (ពីរ)

១-ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ឬ មន្ត្រីតុលាការផ្សេងទៀត មិនអាចក្លាយជាអ្នកទិញ ឬ ជាអ្នកទិញដោយការលក់ដោយបង្ខំ ដោយផ្ទាល់ខ្លួន ឬ តាមរយៈអន្តរការី នូវវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃវិវាទដែលកំពុងចាត់ការនៅតុលាការដែលខ្លួនបំពេញ

ភារកិច្ចបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមេធាវី ឬ សារការី ក្លាយជាអ្នកទិញ ឬ ជាអ្នកទិញដោយការលក់ដោយបង្ខំនូវវត្ថុ ឬ សិទ្ធិដែលទាក់ទងនឹងរឿងក្ដីដែលខ្លួនទទួលបន្ទុក ។

៣-ចំពោះការលក់ទិញដែលផ្ទុយនឹងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ មានតែអ្នកលក់ ភាគីម្ខាងទៀតដែលមានវិវាទអំពីសិទ្ធិ ឬ សន្តតិជនឬប្រតិសិទ្ធិរបស់អ្នកលក់ឬភាគីម្ខាងទៀតទេ ទើបអាចលុបចោលកិច្ចសន្យានេះបាន ។

**មាត្រា ៥២៧.-** វត្ថុដែលអាចលក់បាន

វត្ថុ ឬ សិទ្ធិទាំងឡាយណា ទោះបីជាកើតមានឡើងនាពេលអនាគតក៏ដោយ ក៏អាចយកទៅធ្វើជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញបានដែរ លើកលែងតែវត្ថុ ឬ សិទ្ធិនោះមានលក្ខណៈមិនអាចធ្វើអនុប្បទាន ឬ ច្បាប់ហាមឃាត់មិនឱ្យធ្វើអនុប្បទាន ។

## ផ្នែកទី ៣
## អានុភាពនៃកិច្ចសន្យាលក់ទិញ

**មាត្រា ៥២៨.-** ការផ្ទេរកម្មសិទ្ធិ

១-ចំពោះការផ្ទេរកម្មសិទ្ធិលើកម្មវត្ថុក្នុងកិច្ចសន្យាលក់ទិញ ត្រូវអនុវត្តទៅតាមគោលការណ៍ទូទៅដែលបានកំណត់នៅក្នុងមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង) មាត្រា ១៣៤ (ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) មាត្រា ១៣៥ (ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង) មាត្រា ១៦០ (លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ) និង មាត្រា ១៨៧ (លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។

២-បើកម្មវត្ថុនៃកិច្ចសន្យាលក់ទិញជាសិទ្ធិលើទ្រព្យសម្បត្តិក្រៅពីកម្មសិទ្ធិ ការផ្ទេរសិទ្ធិទាំងនោះ ត្រូវអនុវត្តទៅតាមគោលការណ៍ទូទៅដែលទាក់ទងនឹងការផ្ទេរសិទ្ធិនីមួយៗនោះ ។

## កថាភាគទី ១
## ករណីយកិច្ចរបស់អ្នកលក់

**មាត្រា ៥២៩.-** ករណីយកិច្ចត្រូវពន្យល់របស់អ្នកលក់

អ្នកលក់មានករណីយកិច្ចត្រូវពន្យល់ឱ្យបានច្បាស់លាស់ នូវខ្លឹមសារនៃករណីយ-កិច្ចដែលអ្នកលក់ទទួលបន្ទុក ទំនាក់ទំនងគតិយុត្តដែលទាក់ទងនឹងវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ ហើយជាពិសេសក្នុងករណីលក់អចលនវត្ថុ ត្រូវពន្យល់ដល់អ្នកទិញឱ្យបានច្បាស់លាស់នូវខ្លឹមសារនៃសិទ្ធិ ការទទួលបន្ទុក និង ព្រំដែននៃអចលនវត្ថុ ជាអាទិ៍ ។

**មាត្រា ៥៣០.-** ករណីយកិច្ចទូទៅរបស់អ្នកលក់

អ្នកលក់មានករណីយកិច្ច ត្រូវផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលខ្លួនបានលក់ ត្រូវប្រគល់វត្ថុដែលបានលក់ ត្រូវថែរក្សាទុកនូវវត្ថុដែលបានលក់រហូតដល់ពេលប្រគល់ ព្រមទាំងត្រូវប្រគល់លិខិតផ្សេងៗដែលចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ ចំពោះអ្នកទិញ តាមកិច្ចសន្យា និង បញ្ញត្តិនៃក្រមនេះ ។

**មាត្រា ៥៣១.-** ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់

១-អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការលក់ទិញទៅឱ្យអ្នកទិញ។

២-ប្រសិនបើកម្មវត្ថុនៃការលក់ទិញជាសិទ្ធិរបស់អ្នកដទៃ អ្នកលក់មានករណីយកិច្ចត្រូវទទួលសិទ្ធិនោះ ហើយត្រូវផ្ទេរសិទ្ធិនោះទៅឱ្យអ្នកទិញ ។

៣-ប្រសិនបើអ្នកលក់មិនអាចផ្ទេរសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញទៅឱ្យអ្នកទិញបានទេ អ្នកទិញអាចរំលាយកិច្ចសន្យាបាន ។ ក្នុងករណីនេះ ប្រសិនបើអ្នកទិញមិនបានដឹង នៅពេលធ្វើកិច្ចសន្យាថា សិទ្ធិនោះមិនមែនជាសិទ្ធិរបស់អ្នកលក់ទេ អ្នកទិញអាចទាមទារសំណងនៃការខូចខាតបាន ។

**មាត្រា ៥៣២.-** សិទ្ធិរំលាយកិច្ចសន្យារបស់អ្នកលក់សិទ្ធិអ្នកដទៃ

១-ប្រសិនបើអ្នកលក់មិនបានដឹងថា សិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញមិនមែនជារបស់ខ្លួន នៅពេលធ្វើកិច្ចសន្យាទេ ហើយមិនអាចទទួលយកសិទ្ធិនោះដើម្បីផ្ទេរទៅឱ្យអ្នកទិញបានទេ អ្នកលក់អាចរំលាយកិច្ចសន្យានោះបាន តែត្រូវសងការខូចខាត ។

២-ក្នុងករណីនៃកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើនៅពេលធ្វើកិច្ចសន្យា អ្នកទិញបានដឹងថា សិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញមិនមែនជាសិទ្ធិរបស់អ្នកលក់ទេ អ្នកលក់អាចរំលាយកិច្ចសន្យានោះបាន ដោយមិនចាំបាច់សងការខូចខាត ។

**មាត្រា ៥៣៣.-** ការទទួលខុសត្រូវក្នុងការធានាចំពោះករណីដែលសិទ្ធិមួយភាគជាសិទ្ធិរបស់អ្នកដទៃ

១-ក្នុងករណីសិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ គឺជាសិទ្ធិរបស់អ្នកដទៃ ហើយបើអ្នកលក់មិនអាចទទួលសិទ្ធិនៃភាគនោះដើម្បីផ្ទេរទៅឱ្យអ្នកទិញបានទេ អ្នកទិញអាចទាមទារឱ្យបន្ថយនូវតម្លៃ តាមសមាមាត្រនៃភាគនោះបាន ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើ នៅពេលធ្វើកិច្ចសន្យា អ្នកទិញមិនបានដឹងថា ភាគខ្លះនោះមិនមែនជារបស់អ្នកលក់ទេ ហើយបើទទួលស្គាល់ថា អ្នកទិញនឹងមិនទិញតែភាគដែលសល់តែប៉ុណ្ណោះទេ អ្នកទិញនោះអាចរំលាយកិច្ចសន្យាបាន ។

៣-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ បើនៅពេលធ្វើកិច្ចសន្យា អ្នកទិញមិនបានដឹងថា សិទ្ធិមួយភាគនោះ មិនមែនជារបស់អ្នកលក់ទេ អ្នកទិញក៏អាចទាមទារសំណងនៃការខូចខាតបានដែរ ។

៤-សិទ្ធិដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះ ត្រូវអនុវត្តក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលអ្នកទិញបានដឹងការពិត ក្នុងករណីដែល នៅពេលធ្វើកិច្ចសន្យា អ្នកទិញមិនបានដឹងថា សិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញ មិនមែនជារបស់អ្នកលក់ទេ ឬ គិតចាប់ពីពេលធ្វើកិច្ចសន្យាក្នុងករណីដែលអ្នកទិញបានដឹងថា សិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការ

លក់ទិញមិនមែនជារបស់អ្នកលក់ នៅពេលធ្វើកិច្ចសន្យា ។

**មាត្រា ៥៣៤.-** ការទទួលខុសត្រូវក្នុងការធានាក្នុងករណីដែលមានសិទ្ធិប្រត្យក្សជា ផលុបភោគ ជាអាទិ៍

១-ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញភ្ជាប់ជាមួយសិទ្ធិជួលជាអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ សេវភាព សិទ្ធិជួល សិទ្ធិឃាត់ទុក ឬ សិទ្ធិលើការបញ្ចាំសម្រាប់តតិយជន ហើយបើអ្នកទិញមិនអាចប្រើប្រាស់ ឬ ទទួលផលពីកម្មវត្ថុទាំងមូល ឬ មួយផ្នែក ដោយសារអត្ថិភាពនៃសិទ្ធិនោះ អ្នកទិញដែលមិនបានដឹងអំពីអត្ថិភាពនៃសិទ្ធិនោះ នៅពេលធ្វើកិច្ចសន្យា អាចទាមទារសំណងនៃការខូចខាតពីអ្នកលក់បាន ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើគោលបំណងនៃកិច្ចសន្យាមិនអាចសម្រេចបាន ដោយសារអត្ថិភាពនៃសិទ្ធិនោះ អ្នកទិញដែលមិនបានដឹងអំពីអត្ថិភាពនៃសិទ្ធិនោះនៅពេលធ្វើកិច្ចសន្យា ក៏អាចរំលាយកិច្ចសន្យាបានដែរ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរចំពោះករណីដែលសេវភាពដែលត្រូវមានសម្រាប់អចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ បែរជាគ្មានទៅវិញ ។

៤-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ទី ២ ឬ ទី ៣ ខាងលើនេះ ការរំលាយកិច្ចសន្យា ឬ ការទាមទារសំណងនៃការខូចខាត ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលអ្នកទិញបានដឹងការពិត ។

**មាត្រា ៥៣៥.-** ការទទួលខុសត្រូវក្នុងការធានា ក្នុងករណីដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស

១-ក្នុងករណីដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំដែលកំណត់ថា ម្ចាស់បំណុលមិនប្រើប្រាស់ និង អាស្រ័យផល ឬ មានហ៊ីប៉ូតែកដែលបានដាក់លើអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ នៅពេលដែលអ្នកទិញបានបាត់បង់កម្មសិទ្ធិលើអចលនវត្ថុនោះ ដោយសារសិទ្ធិប្រាតិភោគប្រត្យក្សនោះត្រូវបានអនុវត្ត អ្នកទិញអាចរំលាយកិច្ចសន្យាបាន ។

២-ក្នុងករណីដែលអ្នកទិញបានធ្វើការចំណាយដើម្បីរក្សាកម្មសិទ្ធិ អ្នកទិញអាច

ទាមទារឱ្យអ្នកលក់សងថ្លៃចំណាយនោះមកវិញបាន ។

៣-ក្នុងករណីណាមួយដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ប្រសិនបើអ្នកទិញបានទទួលការខូចខាត អ្នកទិញអាចទាមទារសំណងនៃការខូចខាតនោះបាន ។

៤-ប្រសិនបើអ្នកទិញ បានទិញអចលនវត្ថុដែលភ្ជាប់សិទ្ធិប្រាតិភោគប្រត្យក្សដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងតម្លៃដែលបានដកចេញនូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគប្រត្យក្សនោះរួចហើយ អ្នកទិញនោះពុំមានសិទ្ធិដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះឡើយ ។

**មាត្រា ៥៣៦.-** ការទទួលខុសត្រូវក្នុងការធានាក្នុងការលក់ដោយបង្ខំ

១-អ្នកដែលបានទិញតាមរយៈការលក់ដោយបង្ខំ អាចរំលាយកិច្ចសន្យាចំពោះកូនបំណុល ឬ ទាមទារឱ្យបន្ថយតម្លៃបាន ដោយអនុលោមទៅតាមបញ្ញត្តិពីមាត្រា ៥៣១ (ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់) ដល់មាត្រា ៥៣៥ (ការទទួលខុសត្រូវក្នុងការធានា ក្នុងករណីដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស) នៃក្រមនេះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ ប្រសិនបើកូនបំណុលស្ថិតក្នុងភាពអសាធនីយ អ្នកទិញអាចទាមទារឱ្យម្ចាស់បំណុលដែលបានទទួលចំណែកនៃថ្លៃលក់ សងប្រាក់ដែលបានមកពីការលក់នោះទាំងអស់ ឬ មួយភាគវិញបាន ។

៣-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ប្រសិនបើកូនបំណុលបានដឹងអំពីអត្ថិភាពនៃហេតុ ដែលក្លាយជាមូលហេតុនៃការទទួលខុសត្រូវក្នុងការធានា ហើយមិនបានជូនដំណឹងទៅស្ថាប័នដែលអនុវត្តការលក់ដោយបង្ខំទេ ឬ ម្ចាស់បំណុលបានដឹងហើយ តែនៅតែទាមទារឱ្យលក់ដោយបង្ខំ អ្នកទិញអាចទាមទារនូវសំណងនៃការខូចខាតពីអ្នកទាំងនោះបាន ។

**មាត្រា ៥៣៧.-** ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់សិទ្ធិលើបំណុល

១-អ្នកលក់សិទ្ធិលើបំណុលត្រូវទទួលខុសត្រូវចំពោះអត្ថិភាពនៃសិទ្ធិលើបំណុលនោះ ។

២-ក្នុងករណីដែលអ្នកលក់សិទ្ធិលើបំណុលបានធានាសាធនភាពរបស់កូនបំណុលនោះត្រូវសន្មតថា បានធានាសាធនភាពរបស់កូនបំណុលដែលមាននៅពេលធ្វើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលអ្នកលក់សិទ្ធិលើបំណុលដែលមិនទាន់ដល់ពេលកំណត់ត្រូវសង បានធានាសាធនភាពអនាគតរបស់កូនបំណុល នោះត្រូវសន្មតថា បានធានាសាធនភាពរបស់កូនបំណុលនៅពេលកំណត់ត្រូវសង ។

**មាត្រា ៥៣៨.-** ការព្រមព្រៀងគ្នាក្នុងការអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានា

ទោះបីជាមានការព្រមព្រៀងគ្នាក្នុងការអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានាដែលអ្នកលក់ត្រូវមាន តាមបញ្ញត្តិពីមាត្រា ៥៣១ (ករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់) ដល់មាត្រា ៥៣៧ (ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់សិទ្ធិលើបំណុល) នៃក្រមនេះ ក៏ដោយ ក៏អ្នកលក់មិនអាចរួចផុតពីការទទួលខុសត្រូវបានដែរ ចំពោះហេតុការណ៍ដែលអ្នកលក់បានដឹងតែមិនបានផ្ដល់ដំណឹង ឬ សិទ្ធិដែលខ្លួនបានបង្កើតសម្រាប់តតិយជន ឬ បានធ្វើអនុប្បទានទៅតតិយជន ។

**មាត្រា ៥៣៩.-** ករណីយកិច្ចផ្ដល់វត្ថុដែលគ្មានវិការៈ

១-អ្នកលក់ត្រូវមានករណីយកិច្ចប្រគល់វត្ថុដែលគ្មានវិការៈឱ្យទៅអ្នកទិញ ។

២-លើកលែងតែគូភាគីបានកំណត់ផ្សេង វត្ថុដែលបានប្រគល់ឱ្យទៅអ្នកទិញមានលក្ខណៈណាមួយដូចខាងក្រោមនេះ ត្រូវបានចាត់ទុកថា មានវិការៈ :

ក-វត្ថុនោះមានភាពមិនស្របនឹងចំនួន គុណភាព និង លក្ខណៈដែលបានកំណត់ក្នុងកិច្ចសន្យា ។

ខ-វត្ថុនោះមានភាពផ្សេងពីគំរូដែលអ្នកលក់បានបង្ហាញឱ្យអ្នកទិញមើលចំពោះ

ចំនួន គុណភាព និង លក្ខណៈ ។

គ-វត្ថុនោះមិនស្របនឹងវិធីប្រើដែលអ្នកទិញត្រូវបានបង្ហាញ ដោយជាក់លាក់ ឬ ដោយតុណ្ហីភាព នៅពេលធ្វើកិច្ចសន្យា ។

ឃ-វត្ថុនោះមិនស្របនឹងវិធីប្រើធម្មតានៃវត្ថុប្រភេទដូចគ្នា ។

ង-វត្ថុនោះមិនត្រូវបានខ្ចប់តាមវិធីធម្មតានៃការខ្ចប់វត្ថុប្រភេទដូចគ្នា ឬ តាមវិធីសមរម្យដើម្បីការពារវត្ថុនោះ ។

**មាត្រា ៥៤០.-** ការទទួលខុសត្រូវក្នុងការធានាវិការៈ

១-នៅពេលដែលហានិភ័យត្រូវផ្ទេរទៅអ្នកទិញ បើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញមានវិការៈ ទោះបីជាវិការៈនេះត្រូវបានដឹងច្បាស់នៅក្រោយពេលដែលហានិភ័យត្រូវបានផ្ទេរក៏ដោយ ក៏អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការប្រគល់វត្ថុជំនួស ការជួសជុលវិការៈ ការរំលាយកិច្ចសន្យា ឬ ការបន្ថយនូវតម្លៃ ស្របតាមកិច្ចសន្យា និង បញ្ញត្តិនៃក្រមនេះដែរ ។

២-ទោះបីជាវិការៈកើតឡើងនៅក្រោយពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ប្រសិនបើវិការៈនោះបានកើតឡើងដោយសារអ្នកលក់ធ្វើខុសនឹងករណីយកិច្ចរបស់ខ្លួន ក៏អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការធានាវិការៈ ដូចបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

៣-ក្នុងករណីដែលអ្នកលក់ធានាថា វត្ថុដែលជាកម្មវត្ថុនៃការលក់នោះត្រូវស្របនឹងគោលបំណងធម្មតា ឬ គោលបំណងពិសេស ក្នុងអំឡុងពេលដែលបានកំណត់ក្រោយពីការប្រគល់ ឬ ធានាថា វត្ថុដែលជាកម្មវត្ថុនោះត្រូវរក្សាទុកនូវគុណភាពពិសេស ឬ លក្ខណៈពិសេសដដែល ក្នុងអំឡុងពេលដែលបានកំណត់ក្រោយពីការប្រគល់ ហើយបើមានការបំពានលើការធានានោះ អ្នកលក់ត្រូវទទួលខុសត្រូវក្នុងការធានាវិការៈដូចគ្នាដែរ ។

៤-ក្នុងករណីដែលអ្នកទិញបានដឹង ឬ មិនបានដឹងដោយសារកំហុសធ្ងន់ធ្ងររបស់ខ្លួនអំពីវិការៈនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលធ្វើកិច្ចសន្យាលក់ទិញ អ្នកលក់មិនត្រូវទទួលខុសត្រូវក្នុងការធានាវិការៈនោះទេ ។

**មាត្រា ៥៤១.–** សិទ្ធិជួសជុលរបស់អ្នកលក់

១-ក្នុងករណីដែលអ្នកលក់ប្រគល់វត្ថុដែលមានវិការៈមុនពេលកំណត់ត្រូវប្រគល់ អ្នកលក់នោះអាចជួសជុលវិការៈរហូតដល់ពេលកំណត់នោះបាន លុះត្រាតែមិនបណ្ដាលឱ្យខូចខាតផលប្រយោជន៍ហួសហេតុដល់អ្នកទិញ ។ ប៉ុន្តែ អ្នកទិញមិនត្រូវបានរារាំងក្នុងការអនុវត្តសិទ្ធិទាមទារសំណងនៃការខូចខាតឡើយ ។

២-ទោះបីជាក្រោយពេលកំណត់ត្រូវប្រគល់ក៏ដោយ អ្នកលក់អាចជួសជុលវិការៈទាំងអស់ដោយចេញចំណាយដោយខ្លួនឯងបាន លុះត្រាតែមិនបណ្ដាលឱ្យមានការខូចខាតផលប្រយោជន៍ហួសហេតុដល់អ្នកទិញ ។ ប៉ុន្តែ អ្នកទិញមិនត្រូវបានរារាំងក្នុងការអនុវត្តសិទ្ធិរំលាយ និង សិទ្ធិទាមទារសំណងនៃការខូចខាតឡើយ ។

**មាត្រា ៥៤២.–** សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ

១-អ្នកទិញអាចទាមទារឱ្យអ្នកលក់អនុវត្តករណីយកិច្ចបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកទិញទាមទារការសង្គ្រោះដែលមិនសមស្របនឹងការទាមទារឱ្យអនុវត្តករណីយកិច្ចនោះ ។

២-ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញមានវិការៈ អ្នកទិញអាចទាមទារឱ្យអ្នកលក់ប្រគល់វត្ថុជំនួសដែលគ្មានវិការៈបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការរៀបចំវត្ថុដែលមានប្រភេទដូចគ្នា ដោយអ្នកលក់នឹងបង្កើតបន្ទុកមិនសមរម្យហួសហេតុ ដោយគិតពិចារណានូវកាលៈទេសៈជុំវិញទាំងឡាយ ។

៣-ក្នុងករណីដែលកម្មវត្ថុនៃការលក់ទិញមានវិការៈ អ្នកទិញអាចទាមទារឱ្យអ្នកលក់ជួសជុលវត្ថុដែលជាកម្មវត្ថុនោះបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការជួសជុលវត្ថុដែលជាកម្មវត្ថុដោយអ្នកលក់ នឹងបង្កើតបន្ទុកមិនសមរម្យហួសហេតុ ដោយគិតពិចារណានូវកាលៈទេសៈជុំវិញទាំងឡាយ ។

៤-អ្នកទិញអាចកំណត់អំឡុងពេលសមរម្យបន្ថែមដើម្បីឱ្យអ្នកលក់អនុវត្តករណីយកិច្ចបាន ។ អ្នកទិញមិនអាចទាមទារការសង្គ្រោះចំពោះការបំពានកិច្ចសន្យាក្នុងអំឡុងពេលនេះទេ លើកលែងតែករណីដែលអ្នកទិញទទួលដំណឹងពីអ្នកលក់ថា អ្នកលក់មិនអនុវត្តករណីយកិច្ច

របស់ខ្លួនក្នុងអំឡុងពេលនោះ ។ ប៉ុន្តែ អ្នកទិញមិនត្រូវបាត់បង់សិទ្ធិទាមទារសំណងការខូចខាតដែលបានកើតឡើងដោយសារការយឺតយ៉ាវក្នុងការអនុវត្តករណីយកិច្ច តាមពេលកំណត់ដើមទេ ។

**មាត្រា ៥៤៣.-** សិទ្ធិរំលាយកិច្ចសន្យារបស់អ្នកទិញ

ក្នុងករណីដែលអ្នកទិញមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាលក់ទិញបាន ដោយសារវត្ថុដែលត្រូវបានប្រគល់មានវិការៈ អ្នកទិញនោះអាចរំលាយកិច្ចសន្យានោះបាន ។

**មាត្រា ៥៤៤.-** សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់របស់អ្នកទិញ

ក្នុងករណីវត្ថុដែលត្រូវបានប្រគល់មានវិការៈ ទោះបីជាថ្លៃលក់ត្រូវបានបង់រួចហើយក៏ដោយ ឬ មិនទាន់បង់ក៏ដោយ ក៏អ្នកទិញអាចទាមទារបន្ថយថ្លៃលក់នោះ តាមសមាមាត្រនៃភាពខុសគ្នានៅពេលប្រគល់រវាងតម្លៃនៃវត្ថុដែលគ្មានវិការៈ និង តម្លៃនៃវត្ថុដែលត្រូវបានប្រគល់បានដែរ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកលក់ជួសជុលវិការៈនោះដោយស្របទៅតាមមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) នៃក្រមនេះ ឬ ករណីដែលអ្នកទិញមិនព្រមទទួលសេចក្ដីស្នើផ្ដល់ការជួសជុលរបស់អ្នកលក់ដោយគ្មានមូលហេតុត្រឹមត្រូវ នោះអ្នកទិញមិនអាចទាមទារឱ្យបន្ថយថ្លៃលក់បានឡើយ ។

**មាត្រា ៥៤៥.-** សិទ្ធិទាមទារសំណងនៃការខូចខាតរបស់អ្នកទិញ

អ្នកទិញមិនត្រូវបានរារាំងក្នុងការទាមទារសំណងនៃការខូចខាតដោយស្របទៅតាមបញ្ញត្តិនៃផ្នែកទី ៣ (សំណងនៃការខូចខាត) ជំពូកទី ៤ នៃគន្ថីទី ៤ ដោយមិនអនុវត្ត ឬ ដោយអនុវត្តព្រមគ្នានូវសិទ្ធិដែលបានកំណត់នៅក្នុងបញ្ញត្តិពីមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) ដល់មាត្រា ៥៤៤ (សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់របស់អ្នកទិញ) នៃក្រមនេះទេ ។

**មាត្រា ៥៤៦.-** បញ្ញត្តិពិសេសស្ដីពីដីដែលមានទំហំខ្វះ ឬ លើស

១-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវ

បានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់នូវតម្លៃតាមខ្នាតដីច្បាស់លាស់ តែតាមការពិត ទំហំដីដែលមាននោះមិនគ្រប់នឹងទំហំដែលបានបញ្ជាក់ អ្នកទិញអាចទាមទារឱ្យអ្នកលក់ផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ ឬ បន្ថយនូវតម្លៃដីនោះទៅតាមទំហំដីដែលខ្វះ ឬ រំលាយកិច្ចសន្យា និង ទាមទារសំណងនៃការខូចខាត តាមបញ្ញត្តិពីមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) ដល់មាត្រា ៥៤៥ (សិទ្ធិទាមទារសំណងនៃការខូចខាតរបស់អ្នកទិញ) នៃក្រមនេះបាន លើកលែងតែមានការព្រមព្រៀងផ្សេងរវាងភាគី ។

២-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់នូវតម្លៃ តាមខ្នាតដីច្បាស់លាស់ តែតាមការពិត ទំហំដីដែលមាននោះលើសពីទំហំដែលបានបញ្ជាក់ អ្នកលក់ដែលមិនបានដឹងអំពីការលើសទំហំនោះ ហើយពុំមានកំហុសក្នុងការមិនបានដឹងនោះ អាចទាមទារឱ្យអ្នកទិញបន្ថែមតម្លៃដីដែលលើសនោះបាន លើកលែងតែមានការព្រមព្រៀងផ្សេងរវាងភាគី ។

៣-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់តែតម្លៃដីទាំងមូល ទោះបីជាទំហំដីនោះមិនគ្រប់នឹងទំហំដែលបានបញ្ជាក់ក៏ដោយ ក៏អ្នកទិញមិនអាចទាមទារឱ្យអ្នកលក់ផ្តល់តាវកា-លិកនូវផ្នែកដែលខ្វះ ឬ បន្ថយនូវតម្លៃដីនោះទៅតាមទំហំដីដែលខ្វះ ឬ រំលាយកិច្ចសន្យា ឬ ទាមទារសំណងនៃការខូចខាតបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកលក់បានដឹងអំពីការខ្វះទំហំដីនោះ ឬ ករណីដែលអ្នកលក់បានធានានូវទំហំដីនោះ ឬ ករណីដែលទំហំខ្វះនោះច្រើនជាង ១ ភាគ ២០ (មួយភាគម្ភៃ) ។

៤-ចំពោះដីដែលបានកំណត់ជាក់លាក់ណាមួយ ក្នុងករណីដែលការលក់ទិញត្រូវបានធ្វើឡើងដោយបញ្ជាក់ទំហំ និង កំណត់តែតម្លៃដីទាំងមូល ទោះបីជាតាមការពិតទំហំដីដែលមាននោះលើសពីទំហំដែលបានបញ្ជាក់ក៏ដោយ ក៏អ្នកលក់មិនអាចទាមទារឱ្យអ្នកទិញបន្ថែមតម្លៃដីបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទំហំលើសនោះច្រើនជាង ១ ភាគ ២០ (មួយភាគម្ភៃ) ហើយអ្នកលក់មិនបានដឹងអំពីការលើសទំហំ និង ពុំមានកំហុសក្នុងការមិនបានដឹងនោះ ។

៥-ក្នុងករណីដែលអ្នកលក់ទាមទារបន្ថែមតម្លៃ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី ៤ នៃមាត្រានេះ អ្នកទិញអាចរំលាយកិច្ចសន្យាបាន ។

**មាត្រា ៥៤៧.-** អំឡុងពេលដែលអាចអនុវត្តសិទ្ធិ

១-សិទ្ធិដែលបានកំណត់ក្នុងមាត្រា ៥៤២ (សិទ្ធិទាមទារឱ្យអនុវត្តពេញលេញរបស់អ្នកទិញ) ដល់មាត្រា ៥៤៤ (សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់របស់អ្នកទិញ) និង មាត្រា ៥៤៦ (បញ្ញត្តិពិសេសស្ដីពីដីដែលមានទំហំខ្វះ ឬ លើស) នៃក្រមនេះ ត្រូវអនុវត្តនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ។ ប៉ុន្តែ ចំពោះសិទ្ធិទាមទារសំណងនៃការខូចខាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង វាក្យខណ្ឌទី ២ កថាខណ្ឌទី ៣ នៃមាត្រា ៥៤៦ (បញ្ញត្តិពិសេសស្ដីពីដីដែលមានទំហំខ្វះ ឬ លើស) ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ៤៨២ (អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ) នៃក្រមនេះ ។

២-អំឡុងពេលដែលបានកំណត់ក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគិតចាប់តាំងពីពេលដែលអ្នកទិញបានដឹង ឬ គួរបានដឹងអំពីវិការៈ និង ការខូចខាត រីឯអ្នកលក់វិញ ត្រូវគិតចាប់តាំងពីពេលធ្វើកិច្ចសន្យា ។

**មាត្រា ៥៤៨.-** កិច្ចសន្យាពិសេសដែលអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានាវិការៈ

ទោះបីជាមានការព្រមព្រៀងអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវក្នុងការធានាវិការៈដែលអ្នកលក់ត្រូវមាន តាមបញ្ញត្តិនៃមាត្រា ៥៤០ (ការទទួលខុសត្រូវក្នុងការធានាវិការៈ) នៃក្រមនេះ ក៏ដោយ ចំពោះវិការៈដែលអ្នកលក់បានដឹង តែមិនបានប្រាប់ទេ ក៏អ្នកលក់នេះមិនអាចយកការព្រមព្រៀងអនុគ្រោះ ឬ កម្រិតនូវការទទួលខុសត្រូវនោះ មកអះអាងបានឡើយ ។

**មាត្រា ៥៤៩.-** ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ

១-អ្នកលក់ត្រូវមានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុទៅឱ្យអ្នកទិញ តាមកាលបរិច្ឆេទ និង តាមទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចសន្យា ។

២-ក្នុងករណីដែលកំណត់តែពេលត្រូវបង់ថ្លៃលក់ប៉ុណ្ណោះ នោះត្រូវសន្មតថា ពេលកំណត់នៃការប្រគល់វត្ថុដែលជាកម្មវត្ថុ ក៏ដូចពេលកំណត់នៃការបង់ថ្លៃលក់ដែរ ។

៣-ក្នុងករណីដែលមិនបានកំណត់កាលបរិច្ឆេទដែលត្រូវប្រគល់ផង មិនបានកំណត់កាលបរិច្ឆេទដែលត្រូវបង់ថ្លៃលក់ផង អ្នកលក់មានករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុទៅឱ្យអ្នកទិញ នៅពេលដែលអ្នកទិញទាមទារឱ្យប្រគល់ ។

៤-ក្នុងករណីដែលមិនបានកំណត់ទីកន្លែងដែលត្រូវប្រគល់ទេ ចំពោះការលក់វត្ថុដែលបានកំណត់ជាក់លាក់ អ្នកលក់ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៅទីកន្លែងដែលវត្ថុនោះស្ថិតនៅ នៅពេលធ្វើកិច្ចសន្យា និង ចំពោះករណីក្រៅពីនេះ ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនោះ នៅលំនៅឋានរបស់អ្នកទិញ ។

៥-អ្នកលក់ត្រូវចេញសោហ៊ុយសម្រាប់ប្រគល់ លើកលែងតែមានការព្រមព្រៀងគ្នាពិសេស ។ ប៉ុន្តែ ប្រសិនបើសោហ៊ុយប្រគល់នោះកើនឡើងដោយសារអ្នកទិញបានប្តូរលំនៅឋាន ឬ ដោយសារអំពើអ្វីមួយរបស់អ្នកទិញ អ្នកទិញត្រូវទទួលបន្ទុកបង់នូវចំនួនកំណើននៃសោហ៊ុយនេះ ។

**មាត្រា ៥៥០.-** វិធីប្រគល់

ការប្រគល់វត្ថុត្រូវធ្វើឡើងតាមវិធីប្រគល់កម្មវត្ថុដោយជាក់ស្តែង វិធីប្រគល់ដោយសង្ខេប វិធីផ្ទេរការកាន់កាប់ដោយបញ្ជា ឬ វិធីប្តូរលក្ខណៈនៃការកាន់កាប់ តាមបញ្ញត្តិនៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះ ។ ការប្រគល់អចលនវត្ថុអាចធ្វើឡើងបាន ដោយការប្រគល់សោនៃអាគារ ឬ ប្រគល់ប័ណ្ណបញ្ជាក់សិទ្ធិ ។

**មាត្រា ៥៥១.-** សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា និង សិទ្ធិតវ៉ាដោយមានការបារម្ភ

១-អ្នកលក់អាចប្រកែកមិនព្រមផ្ទេរសិទ្ធិដែលជាកម្មវត្ថុ និង មិនព្រមប្រគល់វត្ថុដែលជាកម្មវត្ថុទៅអ្នកទិញបាន រហូតដល់ពេលដែលអ្នកទិញបានផ្តល់ការសង ចំពោះកាតព្វកិច្ចបង់ថ្លៃលក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកទិញនោះ ពុំទាន់ដល់ពេលកំណត់ត្រូវសង ឬ ករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តករណីយកិច្ចផ្ទេរសិទ្ធិ ឬ កាតព្វកិច្ចប្រគល់ជាមុន ។

២-ទោះបីជាអ្នកលក់បានអនុញ្ញាតឱ្យអ្នកទិញមានពេលកំណត់ដើម្បីសងថ្លៃកម្មវត្ថុក៏ដោយ ប្រសិនបើអ្នកទិញបានក្ស័យធន ឬ បានក្លាយទៅជាមានកង្វះនូវទ្រព្យធន ក្រោយពេលធ្វើកិច្ចសន្យាលក់ទិញ ឬ បានលាក់នូវកង្វះនៃទ្រព្យធន មុនពេលធ្វើកិច្ចសន្យា ក៏អ្នកលក់អាចប្រកែកមិនផ្ទេរសិទ្ធិ និង មិនប្រគល់កម្មវត្ថុនោះបានដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកទិញបានដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការដើម្បីរំលត់ការបារម្ភនោះ ។

**មាត្រា ៥៥២.-** ករណីយកិច្ចរក្សាទុកវត្ថុដែលជាកម្មវត្ថុ

១-អ្នកលក់វត្ថុដែលបានកំណត់ជាក់លាក់ ត្រូវរក្សាទុកវត្ថុនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះទៅអ្នកទិញ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះវត្ថុដែលមិនកំណត់ ក្រោយពីបានកំណត់វត្ថុនោះជាក់លាក់ហើយ ។

២-ក្នុងករណីដែលអ្នកលក់បានធ្វើឱ្យបាត់បង់ ឬ ធ្វើឱ្យខូចខាតវត្ថុដែលជាកម្មវត្ថុដោយសារខ្លួនធ្វេសប្រហែសមិនបានគោរពករណីយកិច្ចត្រូវប្រុងប្រយ័ត្នដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកលក់ត្រូវទទួលខុសត្រូវ ចំពោះអ្នកទិញ តាមកិច្ចសន្យា និង បញ្ញត្តិនៃផ្នែកទី ៣ (សំណងនៃការខូចខាត) ជំពូកទី ៤ គន្ថីទី ៤ នៃក្រមនេះ ។

**មាត្រា ៥៥៣.-** សិទ្ធិទទួលផល

ក្នុងករណីដែលកម្មវត្ថុនៃការលក់បានបង្កើតផលធម្មជាតិមុនពេលប្រគល់ទៅអ្នកទិញ ផលនេះត្រូវទុកជាកម្មសិទ្ធិរបស់អ្នកលក់ លើកលែងតែមានការព្រមព្រៀងគ្នាពិសេសរវាងគូភាគី ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកម្មវត្ថុនៃការលក់បង្កើតផលស៊ីវិលដូចជាថ្លៃឈ្នួល ជាអាទិ៍ ។

# កថាភាគទី ២
# ករណីយកិច្ចរបស់អ្នកទិញ

**មាត្រា ៥៥៤.–** ករណីយកិច្ចទូទៅរបស់អ្នកទិញ

អ្នកទិញត្រូវមានករណីយកិច្ចបង់ថ្លៃជាប្រាក់ដែលសន្យា និង ករណីយកិច្ចទទួលវត្ថុដែលខ្លួនបានទិញ ។

**មាត្រា ៥៥៥.–** ករណីយកិច្ចបង់ថ្លៃទិញ

១-អ្នកទិញមានករណីយកិច្ចបង់ថ្លៃទិញជាប្រាក់ដែលបានកំណត់ក្នុងកិច្ចសន្យា តាមកាលបរិច្ឆេទ និង នៅទីកន្លែងដែលបានកំណត់ក្នុងកិច្ចសន្យា ។

២-ក្នុងករណីនៃការលក់ចលនវត្ថុដែលមានតែកំណត់ពេលនៃការប្រគល់ចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ប៉ុណ្ណោះ ឬ ក្នុងករណីនៃការលក់អចលនវត្ថុដែលមានតែកំណត់ពេលនៃការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ប៉ុណ្ណោះ នោះត្រូវសន្មតថា ពេលកំណត់នៃការបង់ថ្លៃទិញ ក៏ដូចពេលកំណត់នៃការប្រគល់ ឬ ការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីដែរ។

៣-ក្នុងករណីដែលមិនបានកំណត់ពេលប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ពេលធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុផង មិនបានកំណត់ពេលបង់ថ្លៃផង អ្នកទិញមានករណីយកិច្ចបង់ថ្លៃទៅអ្នកលក់ នៅពេលដែលអ្នកលក់ទាមទារឱ្យអ្នកទិញបង់ ។

៤-ក្នុងករណីដែលមិនបានកំណត់ទីកន្លែងដែលត្រូវបង់ថ្លៃទិញនៅក្នុងកិច្ចសន្យាទេ ប្រសិនបើការបង់ថ្លៃត្រូវធ្វើព្រមគ្នានឹងការប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ព្រមគ្នានឹងការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុនោះ អ្នកទិញត្រូវបង់ថ្លៃនៅទីកន្លែងដែលអ្នកលក់ត្រូវប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ត្រូវធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុ ។

**មាត្រា ៥៥៦.-** ការប្រាក់នៃថ្លៃទិញ និង ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ

អ្នកទិញមិនចាំបាច់ត្រូវបង់ការប្រាក់នៃថ្លៃទិញ ឬ ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ រហូតដល់ពេលដែលវត្ថុដែលជាកម្មវត្ថុត្រូវបានប្រគល់ឡើយ ។

**មាត្រា ៥៥៧.-** សិទ្ធិបដិសេធមិនបង់ថ្លៃទិញ ក្នុងករណីដែលតតិយជនអះអាងសិទ្ធិរបស់ខ្លួនលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ

១-ក្នុងករណីដែលមានអ្នកអះអាងសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ ហើយមានការបារម្ភថា អ្នកទិញនឹងបាត់បង់នូវសិទ្ធិទាំងអស់ ឬ មួយភាគដែលខ្លួនបានទិញនោះ អ្នកទិញអាចបដិសេធមិនបង់ថ្លៃទិញទាំងអស់ ឬ មួយភាគ ទៅតាមទំហំនៃហានិភ័យនោះបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកលក់បានដាក់ប្រាតិភោគសមរម្យ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកលក់អាចទាមទារឱ្យអ្នកទិញតម្កល់ថ្លៃទិញបាន ។

**មាត្រា ៥៥៨.-** សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា និង សិទ្ធិតវ៉ាដោយមានការបារម្ភ

១-អ្នកទិញអាចមិនព្រមបង់ថ្លៃទិញបាន រហូតដល់ពេលដែលអ្នកលក់បានផ្តល់នូវការសងចំពោះកាតព្វកិច្ចរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកលក់មិនទាន់ដល់ពេលកំណត់ត្រូវសង ឬ ករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តកាតព្វកិច្ចបង់ថ្លៃជាមុន ។

២-ទោះបីជាអ្នកទិញបានអនុញ្ញាតឱ្យអ្នកលក់មានពេលកំណត់ដើម្បីអនុវត្តកាតព្វកិច្ចក៏ដោយ ប្រសិនបើមានការបារម្ភយ៉ាងជាក់ស្តែងថា អ្នកលក់នឹងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក៏អ្នកទិញអាចប្រកែកមិនបង់ថ្លៃទិញបានដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកលក់បានដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការដើម្បីរំលត់ការបារម្ភនោះ ។

**មាត្រា ៥៥៩.-** ការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ចទទួល

១-ក្នុងករណីដែលអ្នកទិញមានការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ចទទួល អ្នកលក់អាចទាមទារសំណងនៃការខូចខាត ឬ រំលាយកិច្ចសន្យា តាមបញ្ញត្តិនៃផ្នែកទី ៣ (សំណងនៃការខូចខាត) និង ផ្នែកទី ៤ (ការរំលាយកិច្ចសន្យា) ជំពូកទី ៤ នៃគន្ថីទី ៤ បាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើវត្ថុដែលជាកម្មវត្ថុត្រូវបានបាត់បង់ ឬ ខូចខាត ដោយគ្មានកំហុសរបស់អ្នកលក់ អ្នកទិញត្រូវទទួលបន្ទុកហានិភ័យនោះ ។

៣-ក្នុងករណីដែលអ្នកលក់បានផ្ដល់នូវការសង តែអ្នកទិញនៅតែមិនព្រមទទួលវត្ថុដែលជាកម្មវត្ថុ អ្នកលក់អាចតម្កល់ ឬ លក់វត្ថុដែលជាកម្មវត្ថុនោះ តាមបញ្ញត្តិនៃមាត្រា ៤៥៧ (ការតម្កល់) និង មាត្រា ៤៥៨ (សិទ្ធិលក់ដោយខ្លួនឯង) នៃក្រមនេះ បាន ។

## ផ្នែកទី ៤

## ការរំលាយកិច្ចសន្យាលក់ទិញដោយអនុវត្តសិទ្ធិលោះ

**មាត្រា ៥៦០.-** ការសន្យាពិសេសនៃការលោះ

អ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញ ដោយសងប្រាក់ដែលអ្នកទិញបានបង់ និងសងសោហ៊ុយដែលបានកំណត់ក្នុងមាត្រា ៥៦៣ (វិធីអនុវត្តសិទ្ធិលោះ) នៃក្រមនេះ បាន ដោយផ្អែកលើការសន្យាពិសេសនៃសិទ្ធិលោះដែលបានកំណត់ច្បាស់លាស់ នៅក្នុងលិខិតនៃកិច្ចសន្យា ។

**មាត្រា ៥៦១.-** អំឡុងពេលនៃការលោះ

១-អំឡុងពេលនៃការលោះ ចំពោះអចលនវត្ថុ គឺមិនអាចឱ្យលើសពី ៥ (ប្រាំ) ឆ្នាំ បានទេ ចំណែកឯចលនវត្ថុវិញ គឺមិនអាចឱ្យលើសពី ២ (ពីរ) ឆ្នាំ បានទេ ។ ប្រសិនបើបានកំណត់អំឡុងពេលវែងជាងនេះ ត្រូវតែបន្ថយកំណត់នោះដោយស្វ័យប្រវត្តិ មកត្រឹម ៥ (ប្រាំ) ឆ្នាំ ចំពោះអចលនវត្ថុ ហើយមកត្រឹម ២ (ពីរ) ឆ្នាំវិញ ចំពោះចលនវត្ថុ ។

២-ក្នុងករណីដែលគូភាគីបានកំណត់នូវអំឡុងពេលសម្រាប់ការលោះរួចហើយ គូ

# ច្បាប់

# ភូមិបាល

នស/រកម/០៨០១/១៤

អគ្គលេខាធិការដ្ឋាន
ចូល លេខ 1586
ថ្ងៃទី 09-01 ម៉ោង 3.00
បញ្ជូនទៅ

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

